# តម្លៃដី ដែលកាត់ថ្លៃមិនបាន៖
## មរណៈភាព នៃការបណ្តេញចេញ
## នៅភូមិក្បាលស្ពាន


រៀបរៀងរបាយការណ៍ដោយ :

គណៈកម្មាធិការប្រព្រឹត្តិកម្មដែលរួមមានអង្គការ-សមាគមចំនួន ១៨ ជាសមាជិក


សីហា ២០០៥









គណៈកម្មាធិការប្រព្រឹត្តិកម្មដែលរួមមានអង្គការ-សមាគមចំនួន ១៨ជាសមាជិក គឺជាបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលកំពុងបំរើការងារលើបញ្ហាសិទ្ធិមនុស្ស នៅកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទងទូរស័ព្ទលេខ ០១២ ៩៣៤ ៨៦៧ ។

ការបោះពុម្ពផ្សាយនេះ អាចដំណើរការ ទៅបានដោយមានការជួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៏អន្តរជាតិ បេសកកម្មអភិវឌ្ឍន៏ តំបន់/អាស៊ី [U.S Agency for International Development (USAID) Regional Development Mission/Asia] និងវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម [East-West Management Institute, Inc. (EWMI)] នៅក្រោមលក្ខខណ្ឌនៃមូលនិធិលេខ CA No. 442-A-00-03-00193-00 ។ រាល់គំនិត ដែលបានបញ្ចេញនៅក្នុងឯកសារនេះជាគំនិតរបស់អ្នកនិពន្ធ និង មិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់អង្គការ USAID ឬ អង្គការEWMI ទេ ។

EAST · WEST MANAGEMENT INSTITUTE

HUMAN RIGHTS IN CAMBODIA PROJECT

USAID FROM THE AMERICAN PEOPLE

# មាតិកា


| | |
|---|---|
| បុព្វកថា | ១ |
| បញ្ហាដីធ្លីនៅតំបន់ប៉ោយប៉ែត | ៣ |
| ប្រវត្តិទំនាស់ដីធ្លីនៅក្បាលស្ពាន | ៤ |
| ដំណោះស្រាយចំពោះការអនុវត្តន៏សាលក្រម | ១២ |
| អនុសាសន៍ | ១៦ |
| កាលប្រវត្តិ | ២០ |
| កំណត់សំគាល់ | ២២ |

# បុព្វកថា

ករណីសិក្សានេះ គឺជាការពិនិត្យអំពីការអនុវត្តន៍សាលក្រមមានទ្រង់ទ្រាយធំមួយដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៥ កន្លងទៅនេះ នៅភូមិក្បាលស្ពាន ជាប់ព្រំដែនកម្ពុជា- ថៃ ក្នុងឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ។ ការអនុវត្តន៍នេះ បានបណ្តាលអោយមានការបាញ់សំលាប់អ្នកភូមិ ៥ នាក់ ព្រមទាំងបង្កររបួសស្នាមយ៉ាងហោចជាង ៤០នាក់ (ក្នុងនោះ ១៤ នាក់រងរបួសជាទំងន់) និងការឃុំឃាំងជាបណ្តោះអាសន្នមនុស្សចំនួន ៣០ នាក់ ។ អ្នកសារព័ត៌មាន និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ បានឃើញ ហេតុការណ៍ផ្ទាល់ភ្នែកហើយករណីនេះក៏ត្រូវបានផ្សាយយ៉ាងទូលំទូលាយតាមប្រព័ន្ធឃោសនានានា។ ទំហំនៃអំពើហិង្សា និងការបង្ករបួសស្នាមនេះបានធ្វើអោយសាធារណជនតក់ស្លុតយ៉ាងខ្លាំងហើយទោះបីជាយ៉ាងនេះក៏ដោយ រហូតមកដល់ថ្ងៃនេះអាជ្ញាធរនៅតែពុំទាន់បាននាំខ្លួនជន ដែលប្រព្រឹត្តបទល្មើសនេះមកផ្តន្ទាទោសបានជោគជ័យនៅឡើយទេ ។

ករណីភូមិក្បាលស្ពាននេះគឺជាករណីមួយខុសប្លែកពីធម្មតា ប៉ុន្តែក្នុងពេលនោះក៏ជាការឆ្លុះបញ្ចាំងអោយឃើញនូវគ្រោះកម្មនៃសហគមន៍ក្រីក្រដែលទទួលរងការឈឺចាប់បែបនេះ នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។ វាជាករណីខុសប្លែកពីធម្មតាពីព្រោះទំហំនៃអំពើហិង្សាដែលបានផ្ទុះឡើងក្នុងអំឡុងពេលនៃការអនុវត្តន៍សាលក្រមនោះពុំធ្លាប់កើតមានទាល់តែសោះក្នុងការអនុវត្តន៏កន្លងមក ។ ករណីនេះក៏ខុសពីនិន្នាការបច្ចុប្បន្ននៃករណីដីធ្លីដែលកំពុងកើតឡើងនៅក្នុងរាជធានីផងដែរ ដែលជាធម្មតាទាក់ទិនទៅនឹងការដែលរដ្ឋាភិបាលរឹបអូសយកទ្រព្យ-សម្បត្តិដោយគ្មានការសងសំណងត្រឹមត្រូវសោះ។ ប៉ុន្តែករណីខាងលើនេះជាករណីពាក់ព័ន្ធនឹងវិវាទឯកជនមួយតែប៉ុណ្ណោះ។ នេះគឺជាករណីមួយក្នុងចំណោមករណីជាច្រើនដែលសហគមន៍ក្រីក្របានប្តឹងទៅតុលាការដោយសង្ឃឹមថាសិទ្ធិរបស់ពួកគាត់នឹងត្រូវបានការពារ ហើយបាត់បង់ត្រឹមតែដីដែលពួកគាត់អាស្រ័យនៅ និង ជាមូលដ្ឋានក្នុងការរស់នៅតែប៉ុណ្ណោះ ។

ករណីសិក្សានេះមានបំណងលើកយកមកពិភាក្សានូវបញ្ហានិងប្រធានបទដូចខាងក្រោម :

- បញ្ហាដីធ្លីនានានៅតំបន់ប៉ោយប៉ែត
- ប្រវត្តិនៃជំលោះដីធ្លីនៅភូមិក្បាលស្ពាន
- ព្រឹត្តិការណ៍នានាជុំវិញការអនុវត្តន៍សាលក្រម
- ដំណោះស្រាយនានាចំពោះការអនុវត្តន៏សាលក្រម
- ស្ថានភាពបច្ចុប្បន្នរបស់អ្នកភូមិក្បាលស្ពាន
- អនុសាសន៍

ករណីនេះមានភាពស្មុគស្មាញជាទីបំផុត ។ មានប្រជាពលរដ្ឋចំនួន ២១៨ គ្រួសារមានកងកំលាំងសន្តិសុខជាង១០០នាក់ តុលាការចំនួន ៣ មន្ត្រីរដ្ឋាភិបាលនានា និងយ៉ាងហោចមានអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០អង្គការដែលពាក់ព័ន្ធក្នុងករណីនេះ ។ អាស្រ័យដោយបញ្ហាមួយចំនួន យើងពុំអាចជួបអ្នកពាក់ព័ន្ធទាំងនោះបានទេ ។ ពតិមានទាំងឡាយនៅក្នុងរបាយការណ៍នេះទទួលបានពីប្រភពនានាដោយផ្ទាល់ និងទទួលបានពីការស៊ើបអង្កេតភ្លាមៗក្រោយពីព្រឹត្តិការណ៍នោះបានកើតឡើង ។

# បញ្ហាដីធ្លីនៅតំបន់ប៉ោយប៉ែត

ប្រជាពលរដ្ឋនៅតាមតំបន់ជនបទកម្ពុជាភាគច្រើន ជាអនក្ខរជន ហើយជាលទ្ធផលពួកគាត់ប្រឈមនឹងការលំបាកក្នុងការយល់ដឹងអំពីដំណើរការ និង នីតិវិធីនៃការចុះបញ្ជីដីធ្លី ដែលពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន[១] ។ ជនឆ្លៀតឱកាសមួយចំនួនតែងតែឆក់យកឱកាសក្នុងប្រព័ន្ធធ្វើប័ណ្ណកម្មសិទ្ធិដែលមានករណីមួយចំនួនប្រជាជនពុំចង់ ឬពុំមានលទ្ធភាពក្នុងការសូកប៉ាន់ក្នុងការធ្វើប័ណ្ណកម្មសិទ្ធិ ហេតុនេះជាឧសគ្គមួយដែលបង្កឡើងដោយមន្ត្រីរដ្ឋាភិបាល។ ជាលទ្ធផលម្ចាស់ដីផ្ទាល់បានក្លាយទៅជាគ្មានដីធ្លីរស់នៅហើយជនមានអំណាច ដែលមានដីធ្លីយ៉ាងច្រើនកន្លែងរួចហើយ បានទិញដីថែមទៀតដោយការឆ្លៀតកេងយកប្រយោជន៍ពីភាពខ្វះចន្លោះនៃដំណើរការច្បាប់នេះ ។

ករណីដីធ្លីក្នុងខេត្តបន្ទាយមានជ័យបានបង្ហាញនូវលក្ខណៈពិសេសដោយអំពើហិង្សា ការប្រព្រឹត្តដោយមើលងាយមកលើជនរងគ្រោះ និងការលំបាកក្នុងការដោះស្រាយករណីតាមវិធីយុត្តិធមិ និងផលចំណេញរបស់ជនក្រីក្រ[២] ។ បញ្ហានេះមួយភាគធំ គឺជាលទ្ធផលដែលបន្សល់ទុកដោយខ្មែរក្រហមពីអតីតកាលនៅក្នុងខេត្ត និងបញ្ហារីកដុះដាលកាស៊ីណូនាពេលបច្ចុប្បន្ននៅប៉ោយប៉ែតនេះ ។ ការបះបោររបស់ពួកខ្មែរក្រហមមានរយៈពេលវែងជាងតំបន់ផ្សេងៗនៃប្រទេសកម្ពុជាហើយវត្តមានយោធាដ៏ច្រើនកំពុងមានវត្តមាននៅឡើយ។ បន្ទាប់ពីការបើកច្រកព្រំដែនខេត្តអារញ្ញប្រាថេតក្នុងឆ្នាំ ១៩៩៧ ប៉ោយប៉ែតក៏បានក្លាយជាផ្លូវសេដ្ឋកិច្ចដ៏សំខាន់មួយសំរាប់នីហ័រណអហ័រណនៃប្រទេសកម្ពុជា។ ការបើកច្រកព្រំដែននេះ ក៏បាននាំអោយមានកាស៊ីណូយ៉ាងច្រើនដែលជាមុខរបរកាក់កបត្រូវបានកសាងឡើង ដើម្បីទាក់ទាញអ្នកលេងពីប្រទេសថៃដែលនៅទីនោះពួកគេពុំអាចលេងបានដោយសារជាល្បែងខុសច្បាប់។

កត្តាទាំងនេះបាននាំអោយតំលៃដីធ្លីដែលស្ថិតនៅតំបន់ប៉ោយប៉ែតនិងតំបន់ក្បែរព្រំដែនមានការកើនឡើងខ្លាំង ហើយជាផលវិបាក ដែលបានបណ្តាលអោយមានសក្តានុពលខ្ពស់ក្នុងវិបត្តទំនាស់ដីធ្លី ។

# ប្រវត្តិទំនាស់ដីធ្លីនៅក្បាលស្ពាន [៣]

## *សហគមន៍ក្បាលស្ពាន*

ភូមិក្បាលស្ពាន ( ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ) គ្របដណ្តប់លើផ្ទៃដីជិតប្រាំមួយ-ហិកតា។ មានប្រជាជនចំនួន ២០០គ្រួសាររស់នៅ ដែលរកស៊ីចិញ្ចឹមជីវិតជាចំបង គឺការអូសរទេះ ឬ លក់ផលិតផលឆ្លងកាត់ព្រំដែន ។ ភូមិនេះនៅជាប់ទីប្រជុំជនប៉ោយប៉ែត ដែលស្ថិតនៅខាងជើងវត្តដ៏ធំមួយ ( វត្តត្រាច ) និងមានចំងាយប្រហែល ១៥០០ម៉ែត្រ ពីផ្លូវជាតិលេខ ៥ ស្ថិតនៅខាងកើតទំនប់ ក ៥ ។

នៅខាងជើងភូមិ មានទីលានវាយកូនហ្គោលមួយ ដែលជាកម្មសិទ្ធិរបស់កាស៊ីណូមួយ ។ ភូមិផ្សេងៗទៀតមានព្រំប្រទល់ខាងត្បូង ខាងកើត និង ខាងលិចជាប់ភូមិក្បាលស្ពាន ។

មុនឆ្នាំ ១៩៩៧ ដីដែលកំពុងមានបញ្ហានេះជាតំបន់ដែលមានមីនយ៉ាងច្រើនបំផុត ។ ក្នុងឆ្នាំ ១៩៩៧ អាជ្ញាធរស្រុកបានសុំអោយអ្នកស្រុកមួយចំនួន ដែលកំពុងរស់នៅបច្ចុប្បន្នរុះរើទៅតាំងលំនៅលើដីនោះ ។ ពួកគាត់បានកាប់ឆ្ការដី ដែលមានដើមឈើ និងរំដោះគ្រាប់មីនដោយខ្លួនឯង ដែលបណ្តាលអោយអ្នកស្រុកមួយចំនួនបានរងរបួស និងស្លាប់ក៏មាន។ នៅគ្រាដំបូងមានប្រជាជនប្រមាណ ៦០ គ្រួសារប៉ុណ្ណោះ ដែលបានកាន់កាប់ដីទីនោះ ក៏ប៉ុន្តែចំនួននេះបានកើនឡើងយ៉ាងឆាប់រហ័សដោយសារការបើកច្រកព្រំដែនថ្មីៗបានបង្កើតអោយមានឱកាសកាន់តែច្រើនឡើងសំរាប់ប្រជាពលរដ្ឋក្នុងការរកប្រាក់ចំណូល [៤] ។ សហគមន៍មានសមាសភាពអតីតកម្មាភិបាលខ្មែរក្រហមអ្នកតាំងលំនៅជាថ្មីនាពេលបច្ចុប្បន្ន និងអតីតយោធា (ទាំងអ្នកបំរើការបច្ចុប្បន្ន និងអ្នកត្រូវបានកាត់រំសាយដោយភាគច្រើនជាជនពិការ) ។ មន្ត្រីស្រុក ឃុំ និងប្រជាពលរដ្ឋបានសុំស្នើអោយមជ្ឈមណ្ឌលកំចាត់មីនកម្ពុជាដែលហៅកាត់ថា (ស៊ីម៉ាក់)ធ្វើការបោសសំអាតមីន ។ អង្គការស៊ីម៉ាកមិនអាចរកឯកសារផ្លូវការណ៍របស់ខ្លួនស្តីពីការដោះមីននៅក្នុងតំបន់នេះឃើញទេ ដោយគ្រាន់តែបាននិយាយថាខ្លួនបានសំអាតគ្រាប់មីនពីតំបន់នៅក្បែរវត្តត្រាចដែលស្ថិតនៅជាប់ភូមិតែប៉ុណ្ណោះ [៥] ។

អាជ្ញាធរមូលដ្ឋាន បានរៀបចំការវាស់វែង និងការកំណត់ព្រំប្រទល់ ដើម្បីចែកជូនដល់ប្រជាពលរដ្ឋតាមគ្រួសារនីមួយៗដោយមួយគ្រួសារទទួលបាន ( ទំហំ ១០ម x ២០ម) ហើយសហគមន៍បានបង្កើតភូមិមួយដែលមានផ្លូវតូចៗចំនួន ៦ ភ្ជាប់ពីផ្ទះមួយទៅផ្ទះមួយ ។ អាជ្ញាធរបានចេញសៀវភៅគ្រួសារអត្តសញ្ញាណប័ណ្ណ ព្រមទាំងបានរៀបចំហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋាន ដោយបានរៀបចំចំនួនផ្ទះជាក់លាក់សំរាប់ពួកគាត់ ។

## ទិនអូន   ប្រធានភូមិក្បាលស្ពាន

ទិន អូន គឺជាប្រធានភូមិក្បាលស្ពាននៃមុខងារជាផ្លូវការ ប៉ុន្តែគាត់មិនរស់នៅក្នុងភូមិនោះទេ ហើយអ្នកភូមិទាំងនោះបានអះអាងថាពួកគេមិនដែលស្គាល់គាត់ទេ នៅពេលដែលគាត់បានលេចមុខជាលើកដំបូងក្នុង ឆ្នាំ១៩៩៨។ ប្រជាជនមួយចំនួនបានប៉ាន់ស្មានថា ទិន អូន គ្រាន់តែជាបុរសតំណាងអោយមន្ត្រីជាន់ខ្ពស់ណាម្នាក់ប៉ុណ្ណោះ (ដែលគេចង់បានផលប្រយោជន៍នៅលើដីនោះ) ។ ទោះជាប្រជាពលរដ្ឋបានអះអាងបែបនេះក្តី ក៏ពុំមានប្រភពណាមួយបញ្ជាក់អោយបានច្បាស់អំពីបញ្ហានោះដែរ[៦] ។

ក្នុងខែមិថុនា ឆ្នាំ១៩៩៨ ទិន អូន បានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី ។ សំណើនេះ ត្រូវបានចុះហត្ថលេខាដោយអតីតមេឃុំប៉ោយប៉ែត (ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩៨ ព្រមទាំងមានការចុះហត្ថលេខាដោយអតីតអភិបាលស្រុកថែមទៀតផង (ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ១៩៩៨) ។ ទិន អូន បានអះអាងថា គាត់បានទទួលប័ណ្ណកម្មសិទ្ធិ ដើម្បីប្រើប្រាស់នឹងកាន់កាប់ដីដែលចេញដោយអគ្គនាយកដ្ឋានសុរិយោដី។ អ្នកស្រុកបានឮថាដីនោះត្រូវបានគេធ្វើប័ណ្ណកម្មសិទ្ធិរួចហើយ ប៉ុន្តែពួកគាត់បានជឿជាក់ថារឿងនោះវាគ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ។ (បួនឆ្នាំក្រោយមក ការិយាល័យសុរិយោដីស្រុកអូជ្រៅបានចេញលិខិតមួយច្បាប់ដោយសរសេរថា ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីរបស់លោក ទិន អូន ដែលធ្វើនៅឆ្នាំ ១៩៩៨ នោះពុំទាន់មានលក្ខណៈត្រឹមត្រូវតាមច្បាប់នៅឡើយ ហេតុនេះ ការិយាល័យពុំអាចចេញប័ណ្ណកម្មសិទ្ធិអោយបានទេ) ។

ក្នុងឆ្នាំ ១៩៩៩ ទិន អូន បានដាក់ពាក្យបណ្តឹងមួយទៅតុលាការខេត្តបន្ទាយមានជ័យ ដោយប្រកាសអះអាងថា រូបគាត់គឺជាម្ចាស់ដីដែលមានទំហំផ្ទៃ ៥១.២១៤ ម៉ែត្រទ្វេគុណ ហើយដែលមានភូមិនៅលើដីនោះ ។ គាត់បាននិយាយថាគាត់បានកាប់ឆ្ការ និងកាន់កាប់ដីតាំងពី ឆ្នាំ១៩៩៣ ប៉ុន្តែគាត់ត្រូវបានគេចោទថាជាប្រជាជនបានចូលនៅលើដីនោះ ហើយសាងសង់ផ្ទះខុសច្បាប់ ។គាត់ក៏បាននិយាយអះអាងដែរថាក្រៅពីកាប់ឆ្ការដី និងដាំដំណាំ គាត់បានជីក ស្រះទឹកមួយ ប្រឡាយមួយ និងបណ្តាញស្រោចស្រព ហើយថែមទាំងបានបោះបង្គោលរបងនៅលើដីនោះទៀត។

នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ តុលាការខេត្តបន្ទាយមានជ័យ បានសំរេចប្រគល់ដីទៅអោយលោក ទិន អូន កាន់កាប់ដោយស្របទៅនឹងប័ណ្ណកម្មសិទ្ធិដីធ្លីរបស់គាត់ ។

## បញ្ហាដែលពាក់ព័ន្ធនឹងសេចក្តីសំរេចរបស់តុលាការខេត្តបន្ទាយមានជ័យ

- អ្នកភូមិពុំមានឯកសារអ្វីបង្ហាញតាមផ្លូវច្បាប់ទេក្នុងសវនាការនៅតុលាការខេត្តបន្ទាយមាន ជ័យ។
- តាមមើលទៅតុលាការបានសំភាសិតែ ទិន អូន កម្មកររបស់គាត់ និងអ្នកភូមិ ពីរ/បីនាក់តែ
- ប៉ុណ្ណោះ ។ តាមសេចក្តីរាយការណ៍មកថា តុលាការពុំបានហៅមន្ត្រីសុរិយោដី ស្រុក ឬឃុំ ណាម្នាក់ដែលពួកមន្ត្រីទាំងនោះអាចមានលទ្ធភាពធ្វើជាកសិណសាក្សីអោយប្រជាពលរដ្ឋបានទេ[៧] ។

- មានភាពមិនស្របគ្នាដែលមិនអាចពន្យល់បាន អំពីទំហំដីដែលបានអះអាងដោយ ទិន អូន និង
- ទំហំដីជាក់ស្តែង ដែលតុលាការបានសំរេចប្រគល់អោយនោះ ។
- មានការលេចឮថាតុលាការមិនបានយកច្បាប់ស្តីពីការប្រើប្រាស់ដីធ្លីដែលមានស្រាប់មកពិចារណា ទេ ហើយការប្រគល់ដីអោយ ទិន អូននោះគួរតែជាដីប្រើប្រាស់សំរាប់លំនៅដ្ឋានប៉ុណ្ណោះ។ ហើយលើសពីនេះតុលាការថែមទាំងបានប្រគល់ដីច្រើនជាងចំនួនដែលត្រូវអនុញ្ញាតទៅទៀត[៨] ។
- មានសាលក្រមតុលាការពីរ ដែលមានលេខ និងកាលបរិច្ឆេទដូចគ្នា ក៏ប៉ុន្តែមានការវាស់វែង
- ដីខុសគ្នា ។ ការវាស់វែងលើកទីមួយ គ្របដណ្តប់ប្រមាណ ៦.០០០ ម៉ែត្រទ្វេគុណប៉ុណ្ណោះ ហើយការវាស់វែងលើកទីពីរគ្របដណ្តប់ជាង ៤២.០០០ ម៉ែត្រទ្វេគុណ ។ ករណីនេះវាពុំមានភាពច្បាស់លាស់ ថាតើសាលក្រមមួយណាដែលមានសុពលភាព ប៉ុន្តែ តុលាការបានអនុវត្តសាលក្រមមួយដែលគ្របដណ្តប់ផ្ទៃដីដែលធំជាង។ ទោះជាយ៉ាងនេះក្តីក៏ពុំមានការបញ្ជាក់ណាមួយថា សាលក្រមទីពីរ(ដែលមានផ្ទៃធំជាង)ជាសាលក្រមត្រឹមត្រូវទេ ហើយបញ្ហាមួយទៀត គឺតុលាការពុំបានអនុវត្តតាមនីតិវិធីច្បាប់ឡើយ[៩] ។

## *ភស្តុតាងដែលគាំទ្រការអះអាងរបស់សហគមន៍*

- របាយការណ៍មួយ ដែលបានសរសេរដោយអតីតអភិបាលខេត្តបន្ទាយមានជ័យ (របាយការណ៍
- ខេត្ត លេខ ២១៩ ខ.ប.ជ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០៣) បញ្ជាក់ថា មុនឆ្នាំ១៩៩៨ ដីនោះគឺជាតំបន់ព្រៃនៃកន្លែងលាក់ខ្លួនរបស់ចោរព្រៃ និងមានគ្រាប់មីនយ៉ាងច្រើនជាទីបំផុតហើយគ្មានអ្នកស្រុករស់នៅទេ។ របាយការណ៍នេះ បានគាំទ្រដល់កសិណសាក្សីរបស់សហគមន៍[១០] ។
- ក្នុងឆ្នាំ ២០០០ តំណាងក្រសួងទំនាក់ទំនងសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានជួបជាមួយអ្នក ភូមិ និងបានត្រួតពិនិត្យដីនោះ ។ នៅក្នុងកំណត់ហេតុប្រជុំ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០០
- តំណាងរបស់ក្រសួង បានធ្វើការកត់សំគាល់ថា តំបន់ក្បាលស្ពានមានគ្រាប់មីនបង្កប់យ៉ាងច្រើន
- ហើយគ្មានដំណាំ ដើមឈើហូបផ្លែ ឬដាំបង្គោលរបងអ្វីឡើយ។ មានតែប្រឡាយទឹកតូចមួយប៉ុណ្ណោះ ដែលគណៈកម្មាធិការបានធ្វើការកត់សំគាល់ថា ត្រូវបានជីកបន្ទាប់ពីឆ្នាំ ១៩៩៩ ។ លទ្ធផលរកឃើញទាំងនេះ គឺផ្ទុយទៅនឹងការបញ្ជាក់អះអាងរបស់ ទិន អូន ដែលថាគាត់បានដាំដំណាំ និងកសាងប្រព័ន្ធស្រោចស្រព បោះបង្គោលរបង និងប្រឡាយមួយនៅលើដីនោះ ។
- រស់ សារ៉ន ជាមេឃុំប៉ោយប៉ែត បានចេញលិខិតមួយច្បាប់ក្នុងឆ្នាំ ២០០០ ដោយបញ្ជាក់ថា
- ប្រជាជនចំនួន ២១៨ គ្រួសារ បាន និងកំពុងរស់នៅក្នុងក្រុម ៥៥ ភូមិក្បាលស្ពាន ឃុំប៉ោយប៉ែតហើយថាពលរដ្ឋទាំងនោះជាអ្នករងគ្រោះដោយសារជំលោះដីធ្លី[១១] ។

- ឯកសារផ្លូវការ (សៀវភៅគ្រួសារ ។ល។) ចេញដោយអាជ្ញាធរមូលដ្ឋាននោះទទួលស្គាល់ជាពិសេសចំពោះសមាជិកមានឈ្មោះក្នុងសហគមន៍ ថាជាអ្នកស្រុកក្នុងតំបន់ដែលពាក់ព័ន្ធនោះ [១២] ។
- ការិយាល័យសុរិយោដីស្រុកអូរជ្រៅ បានចេញលិខិត (លេខ ៦៨) ចុះថ្ងៃទី ២៤ ខែឧសភា ២០០២ ដោយបានបញ្ជាក់ថា ការដាក់ពាក្យសុំរបស់ ទិន អូន ពុំបានប្រើប្រាស់បែបបទត្រឹមត្រូវដែលចេញដោយក្រសួងរៀបចំដែនដីឡើយ ។ ដូច្នេះ យោងតាមសំដីអនុប្រធានការិយាល័យសុរិយោដីស្រុកអូរជ្រៅ ការដាក់ពាក្យរបស់ ទិន អូន ចុះថ្ងៃទី ១៨ មិថុនា ១៩៩៨ ដើម្បីដំណើរការនិងប្រើប្រាស់ដី គឺពុំត្រឹមត្រូវទេ ហើយពុំអាចចុះបញ្ជីក្នុងការិយាល័យបានឡើយ [១៣] ។

## *បណ្តឹងឧទ្ធរណ៍ និងការអនុវត្តន៍ជាលទ្ធផលនៃការវិនិច្ឆ័យ*

នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០១ សាលាឧទ្ធរណ៍បានចេញសាលដីការមួយគាំទ្រ ទិន អូន ។ ទិន អូន មានមេធាវីម្នាក់ជាតំណាងរបស់គាត់ ប៉ុន្តែ អ្នកភូមិពុំមានមេធាវី ដើម្បីផ្តល់ប្រឹក្សាយោបល់ខាងច្បាប់ទេ ។

បន្ទាប់ពីសាលាឧទ្ធរណ៍បានចេញសាលដីការរួចមក ទិន អូន បានស្នើអោយប្រជាពលរដ្ឋរុះរើទៅភូមិថ្មីមួយដែលមានចំងាយប្រមាណ ៩ គីឡូម៉ែត្រ ។ ប្រជាពលរដ្ឋបានបដិសេធ ពីព្រោះការរកស៊ីចិញ្ចឹមជីវិតរបស់ពួកគាត់គឺផ្អែកលើការចេញចូលព្រៃដែន ហើយចំងាយពីទីកន្លែង ដែលបានស្នើអោយរុះរើទៅនោះមានចំងាយឆ្ងាយពេក ។

## *ព្រឹត្តិការណ៍មុនការអនុវត្តន៍សាលក្រម*

នៅថ្ងៃទី ២៤-២៦ ខែមេសា ឆ្នាំ ២០០២ តុលាការខេត្តបន្ទាយមានជ័យបានអនុវត្តសាលដីការសាលាឧទ្ធរណ៍ហើយបានបណ្តេញអ្នកភូមិទាំងអស់ដោយបង្ខំអោយចេញពីដីនោះ ។ ប្រជាពលរដ្ឋបានរុះរើ ទៅទីកន្លែងមួយដែលនៅជិតភូមិចាស់ ។ អ្នកភូមិបានរាយការណ៍ថា ទិន អូន បានប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់បោះឆ្នោតអោយគាត់ និងគណបក្សនយោបាយរបស់គាត់ គាត់នឹងប្រគល់ដីអោយវិញ ។ ប្រជាជនបានយល់ព្រមហើយនៅចុងឆ្នាំ ២០០២ និងដើមឆ្នាំ ២០០៣ ពួកគាត់បានរុះរើមកនៅលើដីចាស់វិញដោយគ្មានបញ្ហាអ្វីទាំងអស់ ។

តាំងពីពេលអ្នកភូមិបានត្រលប់មកកាន់ដីនោះវិញ ទិន អូន បានធ្វើពាក្យបណ្តឹងមួយច្បាប់ ប្តឹងតំណាងអ្នកភូមិចំនួន ៦នាក់ ពីបទដើរឆ្លងកាត់ដី ។ តំណាងពីរនាក់ត្រូវបានឃាត់ខ្លួន និងបានឃុំឃាំងក្នុងខែកញ្ញា ឆ្នាំ២០០៣។ អង្គការជំនួយផ្នែកច្បាប់កម្ពុជាបានជួយតំណាងទាំងពីរ ហើយពួកគេត្រូវបានដោះលែងក្នុងខែ វិច្ឆិកា ឆ្នាំ២០០៣ ក្រោយពីប្តឹងឧទ្ធរណ៍រួច ។ ប៉ុន្តែរហូតមកដល់ថ្ងៃនេះបទចោទប្រកាន់ ព្រហ្មទ័ណ្ឌក្នុងការរំលោភសិទ្ធិទ្រព្យសម្បត្តិនៅតែរង់ចាំការកាត់ក្តីចំពោះតំណាងទាំងនោះនៅឡើយ ។

តុលាការខេត្ត បានប៉ុនប៉ងដោយមិនបានសំរេចមួយ ក្នុងការអនុវត្តន៍សាលក្រមម្តងទៀតក្នុងខែ ធ្នូ ឆ្នាំ ២០០៣ ដោយប្រឈមមុខនឹងការតស៊ូយ៉ាងមាំ និងដោយសន្តិវិធីរបស់សហគមន៍ ។ បន្ទាប់មកអ្នកភូមិបានចាប់

ផ្តើមបញ្ចុះបញ្ចូលសុំជំនួយ ដោយបានសរសេរលិខិតផ្ញើទៅកាន់ព្រះមហាក្សត្រ ប្រធានរដ្ឋសភាជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ ព្រះមហាក្សត្របានផ្ញើលិខិតមួយច្បាប់ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំអោយមានអន្តរាគមន៍ ក៏ប៉ុន្តែបញ្ហាពុំអាចដោះស្រាយបានទេ ដោយហេតុថាសាលដីការរបស់សាលាឧទ្ធរណ៍បានចូលជាធរមានទៅហើយ ។ តាមមើលទៅ ទិន អួន ក៏បានផ្ញើញត្តិរបស់ខ្លួនផ្ទាល់ព្រមទាំងញត្តិមួយទៀត ដែលមានចំណារគាំទ្រពីនាយករដ្ឋមន្ត្រីផងដែរ ។

## *ការអនុវត្តន៍សាលក្រម*

មានការបកស្រាយផ្សេងៗគ្នាអំពីរបៀបដែលអំពើហិង្សាទាំងនោះបានកើតឡើង និងអំពីអ្វីដែលបានកើតឡើងនៅពេលបន្ទាប់មក ។ មានការពន្យល់ផ្សេងៗគ្នាជាច្រើនអំពីទំហំដីទំនាស់នោះ និង ចំនួនកងកំលាំងសន្តិសុខប្រដាប់ដោយអាវុធដែលបានពាក់ព័ន្ធក្នុងអំពើហិង្សានោះផងដែរ ។ ករណីសិក្សានេះមានបំណងបង្ហាញនូវការពន្យល់ដែលអាចមានភាពត្រឹមត្រូវយ៉ាងច្រើន អំពីព្រឹត្តិការណ៍នៃការអនុវត្តសាលក្រមនោះ ។

## *ការផ្តល់ដំណឹងអំពីការអនុវត្តន៍សាលក្រម*

បន្ទាប់ពីមានសំណើពី ទិន អួន ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៥ តុលាការខេត្តបន្ទាយមានជ័យបានចុះអនុវត្តន៍សាលក្រមជាលើកទីបី ។ ការបណ្តេញចេញបានកើតឡើងនៅថ្ងៃ ច័ន្ទ ទី ២១ ខែមីនា ឆ្នាំ២០០៥ ។

ព្រះរាជអាជ្ញា និងក្រឡាបញ្ជីតុលាការខេត្តបន្ទាយមានជ័យបានប្រកាសថា គេបានជូនដំណឹងដល់អ្នកភូមិ និងអាជ្ញាធរឃុំមួយខែមុនពេលអនុវត្តសាលក្រមនេះ ។ អាជ្ញាធរឃុំបដិសេធថាពុំបានទទួលសេចក្តីជូនដំណឹងជាផ្លូវការទេ ហើយថាខ្លួនបានមកដល់ទីកន្លែងកើតហេតុក្រោយពេលដែលមានការបាញ់ប្រហារកើតឡើងរួចហើយ ។

តាមមើលទៅសហគមន៍បានទទួលការជូនដំណឹងខ្លះៗថា នឹងមានការអនុវត្តន៍សាលក្រម ។ ក្នុងខណៈនោះពួកគាត់បានបដិសេធចោលនូវការជូនដំណឹងជាផ្លូវការ ហើយពួកគាត់ត្រូវបានព្រមានដោយតំណាងរបស់ ទិន អួន ហើយពួកអ្នកភូមិបានត្រៀមកាំបិត ពូថៅ ដំបង ប្រេងសាំង និងទឹកអាស៊ីតរួចជាស្រេច ដើម្បីតទល់ ។

## *កំលាំងសន្តិសុខដែលពាក់ព័ន្ធ*

ប្រភពផ្សេងៗ បានផ្តល់តួលេខខុសៗគ្នាអំពីកំលាំងសន្តិសុខ ។ អ្នកភូមិ និងអង្គការមិនមែនរដ្ឋាភិបាល (ដែលភាគច្រើនមានវត្តមាន) ប្រកាសថា កំលាំងសន្តិសុខមានចំនួនប្រមាណ ២៤០ នាក់ ។ ប៉ុន្តែក្រឡាបញ្ជីបានបញ្ជាក់ថាមានចំនួន ១១៩ នាក់ប៉ុណ្ណោះ គណៈកម្មការស៊ើបសួរដែលបញ្ជាដោយរដ្ឋាភិបាល បាននិយាយថាមាន ១២៤ នាក់ ។ ក្រៅពីកងកំលាំងរាជអាវុធហត្ថ ប៉ូលីសក្នុងឯកសណ្ឋាន និងមន្ត្រីនានា សាក្សីមួយចំនួនបាន

និយាយថាមានក្រុមប្រដាប់អាវុធទីពាមួយក្រុមទៀត ដែលស្លៀកពាក់ជាឯកសណ្ឋានពណ៌ប្រផេះចាស់ហើយគ្មានផ្លាកសញ្ញាសំគាល់ទេ បានចូលរួមក្នុងការអនុវត្តន៏នោះ ថែមទាំងបានរឹបអូសយកម៉ាស៊ីនថតពីសាក្សីទៀតផង ។

យោងទៅតាមការស៊ើបអង្កេតដោយអង្គការអាដហុក និងគណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្ស របាយការណ៍របស់សាក្សី និងការពន្យល់របស់សារពត៌មាន បានរាយការណ៍ថា គេឃើញមានរថយន្តពន្លត់អគ្គីភ័យមួយគ្រឿង និងគ្រឿងចក្រឈូសឆាយពីរគ្រឿង ដោយមានកម្មកររុះរើ ៥០ នាក់បានអមដោយកំលាំងសន្តិសុខ ។

មុនការអនុវត្តន៏ កំលាំងសន្តិសុខបានជួបជាមួយក្រឡាបញ្ជីតុលាការ ចាន់ សាវ៉ាត នៅក្នុងភោជនីយដ្ឋានមួយនៅប៉ោយប៉ែត ដើម្បីពិភាក្សាអំពីដំណើរការក្នុងការអនុវត្តន៏ ។ ចាន់ សាវ៉ាត បាននិយាយអះអាងថា គាត់បានណែនាំកំលាំងអោយជៀសវាងប្រើប្រាស់អំពើហិង្សា នឹងមិនអោយបាញ់ទេ ។ បន្ទាប់មកពួកគេបានបំបែកជាក្រុមតូចៗ រួចឆ្ពោះទៅកាន់ភូមិនោះតែម្តង[១៤] ។

## ការមកដល់របស់កំលាំងប្រដាប់អាវុធ និង ការចាប់ផ្តើមការអនុវត្តន៍សាលក្រម

កំលាំងប្រដាប់អាវុធបានមកដល់នៅចន្លោះម៉ោង ៨:០០ និង ៩:០០ ព្រឹក ហើយបានឈរព័ទ្ធជុំវិញភូមិ ។ របាយការណ៏ដំបូងរបស់គណៈកម្មាធិការ ដែលបានបង្កើតឡើង ដើម្បីស្រាវជ្រាវការបាញ់ប្រហារនោះក៏បានរាយការណ៍ថា កំលាំងត្រូវបានបែងចែកជាបួនផ្នែក ហើយផ្នែកនីមួយៗឈរជើងនៅជ្រុងភូមិនីមួយៗ[១៥] ។

ការអនុវត្តន៏បានចាប់ផ្តើមប្រហែលម៉ោង ៩:៣០ព្រឹក ប៉ុន្តែពេលវេលាពិតប្រាដកនៃព្រឹត្តការណ៏នៅមិនទាន់ច្បាស់លាស់នៅឡើយ ។ ការពន្យល់របស់សាក្សីជាច្រើនបញ្ជាក់ថា ចាន់ សាវ៉ាត បានចាប់ផ្តើមអានសាលក្រមតុលាការខ្លែងៗ ក្នុងខណៈពេល ដែលផ្ទះកំពុងត្រូវបានឈូសឆាយនឹងដុតបំផ្លាញ[១៦] ឬបញ្ជាក់ថាគាត់បានអានសាលក្រមបន្ទាប់ពីការបាញ់បានកើតឡើង ។ ចាន់ សាវ៉ាត ខ្លួនឯងប្រកាសថា គាត់មិនបានឃើញការបាញ់ចាប់ផ្តើមដោយរបៀបណាទេ ឬកំលាំងត្រូវបានពង្រាយក្នុងភូមិដោយរបៀបណានោះក៏ទេដែរ ។ គាត់បាននិយាយថា គាត់នៅចំងាយប្រហែល២០០ម៉ែត្រ ពីកន្លែងកើតហេតុ ហើយថានៅពេលឮសំលេងបាញ់ គាត់បានក្រាបចុះដល់ដីរហូតដល់ការបាញ់បានបញ្ចប់ ។ គាត់បាននិយាយថា ការបាញ់មានរយៈពេលប្រមាណ ១០ នាទី[១៧] ។ ប៉ុន្តែនៅពេលសំភាសន៏គាត់ពុំបានបញ្ជាក់អោយបានច្បាស់លាស់ស្តីពីទីកន្លែង ដែលគាត់បានឈរអានសាលក្រមនោះទេ ។

## ការផ្ទុះឡើងនូវអំពើហិង្សា

ពុំទាន់មានភាពច្បាស់លាស់នៅឡើយថាតើកំលាំងសន្តិសុខបានធ្វើអ្វីខ្លះនៅពេលពួកគេបានមកដល់ ព្រមទាំងមានការពន្យល់ខុសៗច្រើនអំពីរបៀបដែលអំពើហិង្សានោះបានកើតឡើង ។

យោងតាមសារព័ត៌មាន[១៨]និងការសាក្សីដែលបានឃើញផ្ទាល់ភ្នែកបាននិយាយថាការអនុវត្តន៏សាលក្រម នោះបានចាប់ផ្តើមដោយប៉ូលីលបានបាញ់គំរាមឡើងទៅលើ ពេលដើរក្នុងភូមិ ហើយក៏ចាប់ផ្តើមចាប់អ្នកភូមិ។ អ្នកភូមិបានគប់ដុំថ្ម និងវត្ថុផ្សេងៗទៅលើកងកំលាំង រីឯកងកំលាំងប្រដាប់អាវុធបានបាញ់តបវិញ ដោយការបាញ់សំដៅទៅលើប្រជាពលរដ្ឋ ហើយបានចាប់អ្នកណា ដែលត្រូវបានដេញតាមទាន់តែម្តង ។

ព្រះរាជអាជ្ញា ងួន ថុល (ដែលពុំមានវត្តមាន ក្នុងពេលអនុវត្តន៏សាលក្រម) បានបញ្ជាក់ថាប្រជាពលរដ្ឋបានចាប់ផ្តើមប្រព្រឹត្តអំពើហិង្សាមុន ដោយគប់កាំបិតទៅលើកងរាជអាវុធហត្ថម្នាក់ ហើយកងកំលាំងក៏បានបាញ់តបវិញភ្លាមៗដែរ ។ ថុល បាននិយាយថា កងកំលាំងគ្រាន់តែបាញ់ឡើងលើ និងភ្ជុចចុះដីតែប៉ុណ្ណោះ ។ គាត់បានបញ្ជាក់ថា គាត់បានណែនាំអោយជៀសវាងអំពើហិង្សា និងការបាញ់ ហើយប្រសិនបើមានបញ្ហាកំលាំងគួរធ្វើការចចារជាមួយតំណាងប្រជាពលរដ្ឋ ។

ភាពច្បាស់លាស់តែមួយគត់ គឺគេបានបាញ់កាំភ្លើង ដែលបណ្តាលអោយអ្នកភូមិស្លាប់ និងរងរបួស ហើយផ្ទះរបស់ពួកគាត់ត្រូវបានដុតរុះរើកំទេចចោល ។

មានការអះអាងថាប៉ូលីស បានបាញ់ត្រង់ៗលើប្រជាពលរដ្ឋ ដែលហាក់ដូចជាមានការគាំទ្រ ដោយប្រជាពលរដ្ឋមួយចំនួនដែលត្រូវបានបាញ់សំលាប់ក្នុងអំឡុងពេលអនុវត្តន៏សាលក្រមនោះ អ្នកទាំងនោះមានឈ្មោះ :

១- លោក ពេជ្រ ប៊ុនធឿនអាយុ ៤០ ឆ្នាំ ត្រូវបានបាញ់ ៤ គ្រាប់ហើយស្លាប់ភ្លាម ។
២- លោក សៀន សុក អាយុ ៤៤ ឆ្នាំ ត្រូវបានបាញ់ចំដើមទ្រូងខាងស្តាំរបស់គាត់ ហើយស្លាប់ភ្លាម ។
៣- លោក គឹម សំបាន អាយុ ៣៩ ឆ្នាំ ត្រូវបានបាញ់ចំដើមទ្រូង ហើយស្លាប់ភ្លាម ។
៤- លោក ថាម ប៊ុនធិន អាយុ ៣៨ ឆ្នាំ ត្រូវបានបាញ់ ហើយស្លាប់ភ្លាម ។
៥- លោក កន គឿន អាយុ ៣៩ ឆ្នាំ ត្រូវបានបាញ់ចំពោះ និងជើងខាងស្តាំ ។ ជនរងគ្រោះនេះជាជនពិការ ។ បន្ទាប់មកគាត់បានស្លាប់នៅក្នុងមន្ទីរពេទ្យ ។

## *ការពន្យល់រៀបរាប់របស់សាក្សី*

ទោះជារបាយការណ៏សាក្សីមួយចំនួនមានភាពផ្ទុយគ្នា ដោយពួកគាត់ជាច្រើនបានស្ថិតនៅកន្លែងផ្សេងៗគ្នា ហើយបានឃើញព្រឹត្តិការណ៏នោះពីទិដ្ឋភាពខុសៗគ្នាក៏ដោយ តែពួកអ្នកភូមិភាគច្រើនបានអះអាងដូចៗគ្នាអំពីភាពចរិតសាហាវរបស់កងកម្លាំងនគរបាលនៅក្នុងការអនុវត្តន៏សាលក្រមនោះថាជាអំពើសាហាវឃោឃៅជាទីបំផុត ។

ស្ត្រីម្នាក់ដែលប្តីរបស់នាងត្រូវបានគេបាញ់ស្លាប់ក្នុងចំណោមអ្នកស្លាប់ទាំងនោះ បាននិយាយថា " ប្តីខ្ញុំបានព្យាយាមរត់ចេញពីផ្លូវ ប៉ុន្តែពេលដែលគាត់រត់បានប្រហែល ១០ ម៉ែត្រ គាត់ត្រូវបានបុរសម្នាក់ឈ្មោះ សារ៉ុន បាញ់

ហើយបុរសនោះស្លៀកពាក់ឯកសណ្ឋាននគរបាល ។ បន្ទាប់មក សារ៉ុន បានបាញ់គាត់ពីរគ្រាប់ថែមទៀត --- សារ៉ុន ក៏បានភ្ជង់កាំភ្លើងដាក់ខ្ញុំដែរ ហើយថែមទាំងបានឃាត់មិនអោយខ្ញុំទៅជួយប្តីខ្ញុំទៀតផង ។

អ្នកភូមិម្នាក់ទៀតបានរៀបរាប់ថា គាត់ត្រូវបានបុរសម្នាក់ស្លៀកពាក់ស៊ីវិល វាយដោយព្រនង់ឬស្សី ហើយបណ្តាលអោយមុតយ៉ាងវែងរហូតដល់ ៦ សម នៅលើក្បាលគាត់ ហើយក្នុងពេលនោះក៏មានសមាជិកកងសន្តិសុខម្នាក់បានស្រែកថា "ហេតុអ្វី បានជាអ្នកឯងមករស់នៅលើដីរបស់អញ? អញនឹងវាយពួកឯងរហូតដល់ស្លាប់" ។ អ្នកភូមិខ្លះទៀតបានរៀបរាប់ថា ពេលដែលកងកំលាំងព័ទ្ធអ្នកភូមិជុំវិញ មានកងកំលាំងមួយចំនួនស្រែកថា" យើងនឹងធ្វើការបង្ហូរឈាម" ។

មានការចោទប្រកាន់ថា កងកំលាំងប្រដាប់អាវុធទាំងនោះបានដកយកលុយ ទូរស័ព្ទដៃ និងនាឡិការដៃពីសពដែលបានស្លាប់ពេលនោះ ព្រមទាំងបានរើកកកាយផ្ទះទាំងនោះមុនពេលដែលពួកគេដុតបំផ្លាញ ។ ស្ត្រីមានផ្ទៃពោះម្នាក់ដែលប្តីរបស់នាងត្រូវបានគេបាញ់ស្លាប់ សុំនគរបាលចូលក្នុងផ្ទះដើម្បីយកឆ្នាំងបាយ ហើយនគរបាលបានឆ្លើយតបមកនាងវិញថា" បើអញជាមនុស្សចិត្តល្អ នោះអញនឹងមិនមានមុខនៅទីនេះទេថ្ងៃនេះ" ។

ការអះអាងរបស់សាក្សីផ្សេងៗទៀតដែលបានឃើញផ្ទាល់ភ្នែកបាននិយាយថា :

- អ្នកភូមិបានកំពុងចាក់ផ្សាយសុន្ទរកថាដែលបានថតទុក របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានថ្លែងអំពីការរំលោភយកដីធ្លី ។ គេបាននិយាយថានគរបាលបានបាញ់ឧឃោសនស័ព្ទ (ប្រដាប់បំពងសំលេង ឬមេក្រូ) ពេលដែលអំពើហិង្សានោះកំពុងផ្ទុះឡើង ។
- អ្នកភូមិម្នាក់បាននិយាយថា គាត់បានសុំអាជ្ញាធរ ថាតើពួកគាត់អាចចូលយកសំភារៈក្នុងផ្ទះបានដែរឬទេ មុននឹងផ្ទះរបស់ពួកគាត់ត្រូវបានដុតចោលនោះ មន្ត្រីប៉ូលីសម្នាក់បានអោយគាត់ទៅសុំការអនុញ្ញាតពីមេរបស់គាត់ ហើយនៅពេលដែលគាត់បានត្រលប់មកវិញ ពួកគាត់បានឃើញ ប៉ូលីសនិងកងរាជអាវុធហត្ថកំពុងយករើកកាយយកសំភារៈរបស់គាត់ ។ ពេលនោះពួកគាត់ សួរថាហេតុអ្វីបានអាជ្ញាធរយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គាត់ដូច្នេះ ពេលនោះមន្ត្រីអាជ្ញាធរ ម្នាក់ក៏បានវាយដំអ្នកភូមិនោះយ៉ាងដំណំ ។
- ក្នុងចំណោមកំលាំងប្រដាប់អាវុធដែលមានវត្តមាន មានបុរសម្នាក់ឈ្មោះ ពៅ ឬ ប៉ីរ ផល្លី [១៩] ដែលកាន់កាំភ្លើងមួយដើមបានបាញ់ក្នុងពេលធ្វើការអនុវត្តន៍សាលក្រមនោះ ។ គេបាននិយាយថាគាត់បាន ស្លៀកពាក់ឯកសណ្ឋានជាប៉ូលីស ប៉ុន្តែគាត់ពុំមែន ជាមន្ត្រីប៉ូលីសទេ ។
- អ្នកភូមិមួយចំនួនបានចោទប្រកាន់ថា កងកំលាំងប្រដាប់ដោយអាវុធជាច្រើន ដែលបានបញ្ជាអោយបំផ្លាញផ្ទះនោះ គឺស្លៀកពាក់សំលៀកបំពាក់ជាស៊ីវិល ។

# ដំណោះស្រាយចំពោះការអនុវត្តន៍សាលក្រម

## *ការដោះស្រាយរបស់រដ្ឋាភិបាល*

មានការស្រែកឈឺឆ្អាលភ្លាមៗ បន្ទាប់ពីឧប្បទ្ទវហេតុបានកើតឡើង ហើយមន្ត្រីរដ្ឋាភិបាលនានាបានធ្វើដំណើរទៅកាន់ភូមិនោះភ្លាមៗ ដើម្បីសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះ។ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស្រ៊ុន វង្សវណ្ណៈ រួមជាមួយ និងអភិបាលខេត្តបន្ទាយមានជ័យ ហេង ចាន់ថា បានទៅជួបសំណេះសំណាលជាមួយអ្នកភូមិ ហើយពួកគាត់បានសំដែង នូវសមានទុក្ខចំពោះឧប្បទ្ទវហេតុដែលកើតឡើងនោះ ព្រមទាំងបានសន្យានឹងបង្កើតគណៈកម្មការស៊ើបអង្កេតមួយ ដោយផ្អែកលើបទបញ្ជាពីនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[២០] ។ សមាជិករដ្ឋសភារួមមាន ខៀវ សន ម៉ម ស៊ីផាន និងសុន ឆ័យ ក៏បានជួបសំណេះសំណាលជាមួយអ្នកភូមិផងដែរ។ មួរ សុខហួរ និងគឹម សុភារិទ្ធិ មកពីគណបក្សសម រង្ស៊ីក៏បានទៅកាន់តំបន់ក្បាលស្ពាននេះដែរ ។ រដ្ឋាភិបាល និងមន្ត្រីខេត្តបានផ្តល់ជំនួយបណ្តោះអាសន្នដលពលរដ្ឋក្នុងសហគមន៍នោះ ។ អ្នកភូមិក៏បានរាយការណ៍ដែរថា មន្ត្រីជាច្រើនបានសន្យាជាមួយពួកគាត់ថានឹងជុំរុញសេចក្តីសំរេចចិត្តអោយបានឆាប់ៗយ៉ាងយូរមួយសប្តាហ៍ ប៉ុន្តែការសន្យានោះពុំទាន់ឃើញមានលទ្ធផលអ្វីកើតឡើងទេ[២១] ។

ឱម យិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល បានបញ្ជាក់ថា ករណីនេះនឹងតំរូវអោយមានការស៊ើបអង្កេតយ៉ាងល្អិតល្អន់មួយ ហើយគណៈកម្មាធិការនេះ នឹងពិនិត្យមើលបញ្ហានោះ[២២] ។ ហេង សំរិន ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជាបាននិយាយថា រដ្ឋាភិបាល "មិនអើពើ " ហើយ "ការខ្វះខាតក្នុងការត្រួតពិនិត្យទូទៅ" គឺជាមូលហេតុបង្កអោយមានអំពើហិង្សានៅក្នុងភូមិក្បាលស្ពាននេះ[២៣] ។

## *ការស៊ើបអង្កេតរបស់រដ្ឋាភិបាល*

រដ្ឋាភិបាលបានប្រគល់ការស៊ើបអង្កេត ទៅគណៈកម្មការស៊ើបសួរ ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៥ ។ ប្រធានគណៈកម្មការ គឺជាអភិបាលរងខេត្តបន្ទាយមានជ័យ ។ គណៈកម្មការនេះក៏រួមមានស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថ និងអាជ្ញាធរខេត្តផ្សេងៗទៀតផងដែរ[២៤] ។

គណៈកម្មការនេះ បានចេញរបាយការណ៍ជាបឋមចំនួនពីរ ។ របាយការណ៍ទីមួយ បានរកឃើញថាមានកំលាំងពាក់ព័ន្ធព្រមទាំងបានរកឃើញឈ្មោះអ្នកទទួលខុសត្រូវលើកំលាំងនោះទៀងផង ។ របាយការណ៍បានបន្ថែមថាថ្នាក់លើរបស់កំលាំងប្រដាប់អាវុធទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះបញ្ហាដែលបានកើតឡើងក្នុងអំឡុងពេលអនុវត្តសាលក្រមនោះ ។ នគរបាលស្រុកអូរជ្រៅពីរនាក់ឈ្មោះ មុយ ឈុន និង តាន់ ភីរម្យ ត្រូវបានឃុំឃាំងជាបណ្តោះអាសន្នដោយគណៈកម្មការនៅឯស្នងការដ្ឋាននគរបាលខេត្ត ដើម្បីធ្វើការស៊ើបអង្កេត

បន្ថែម ។ មន្ត្រីអាវុធហត្ថ១១ នាក់ ដែលបានសារភាពថា បានបាញ់កាំភ្លើងរបស់ខ្លួន គឺត្រូវបានដាក់អោយស្ថិតនៅក្រោមការឃ្លាំមើលដោយថ្នាក់លើរបស់ពួកគេ ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម ។

របាយការណ៍ទីពីរ បានបញ្ជាក់អះអាងអំពីចំនួនកំលាំង[២៥] ដែលបានចូលរួម ហើយបានរកឃើញថាមានក្រុមមួយផ្សេងទៀតដែលមានប្រយោជន៍ក្នុងរឿងដីនេះ។ គណៈកម្មការកំពុងធ្វើការស៊ើបអង្កេតស្វែងរកជនដែលនៅពីក្រោយក្រុមនេះ ។ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ នគរបាលខេត្តបានចាប់ខ្លួន ឈ្មោះ ពៅ ឬ ប៉រ ផល្លី ដែលត្រូវបានចោទប្រកាន់ថា បានបាញ់អ្នកភូមិក្នុងពេលអនុវត្តន៍សាលក្រមនោះ[២៦] ។ ប៉ូលីសស្រុកក៏បានសួរចំលើយម្ចាស់ឧបករណ៍គ្រឿងចក្រធុនធ្ងន់ ដែលគាត់បានជួលគ្រឿងចក្រឈូសឆាយ និងឡានទឹកទៅអោយទិន អូន ។ គណៈកម្មការ បានកត់សំគាល់ថា ទិន អូន បានរត់គេចពីតំបន់នេះ ហើយប៉ូលីសកំពុងស្វែងរកគាត់ ។

គេបានឮថា គណៈកម្មការនោះបានចុះទៅភូមិក្បាលស្ពានតែម្តងគត់ ហើយអ្នកភូមិបាននិយាយថា គណៈកម្មការនោះពុំបានសំភាសន៏ពួកគាត់ទេក្នុងពេលនោះ ។ ហើយលើសពីនេះទៅទៀតអ្នកភូមិបានមានការសង្ស័យថា "យ៉ាងតិចក៏មានសមាជិកម្នាក់ក្នុងជួរគណៈកម្មការ ដែលបានចូលរួមក្នុងពេលអនុវត្តន៏សាលក្រមនោះ។ គណៈកម្មការពុំបានផ្តល់របាយការណ៏ណាមួយអោយតុលាការដែលពាក់ព័ន្ធទេ ។

## *លទ្ធផលនៃការចោទប្រកាន់*

មានការប្តឹងកងកំលាំងទាំងនោះទៅតុលាការខេត្តបន្ទាយមានជ័យ ប៉ុន្តែត្រូវបានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទេរអំណាចទៅអោយតុលាការខេត្តបាត់ដំបងជាអ្នកចាត់ការវិញ។ តុលាការខេត្តបាត់ដំបងបានធ្វើការស៊ើបអង្កេតព្រមទាំងបានធ្វើការចោទប្រកាន់ពីបទឃាតកម្ម ប៉ុនប៉ងធ្វើឃាត មនុស្សឃាតដោយចេតនា និងបង្ករបួសស្នាមដែលបានចោទកងរាជអាវុធហត្ថ និង ប៉ូលីសសរុបចំនួន ៦៦ នាក់ និងអ្នកភូមិ៥២នាក់ (រួមទាំងអ្នកភូមិស្លាប់ ៤ នាក់ផង)[២៧] ។ មនុស្ស ៤ នាក់ត្រូវបានជាប់ឃុំឃាំងក្នុងពន្ធនាគារដោយត្រូវបានចោទពីបទមនុស្សឃាត ប៉ុនប៉ងធ្វើឃាត និងមនុស្សឃាតដោយចេតនា ហើយអ្នកទាំងនោះមានឈ្មោះ :តាន់ ភីរុណ, ប៊ិន សំបិន, ប៉រ ឬពៅ ផល្លី និង នឹម ផាន ។

តុលាការបានសំភាសន៏មន្ត្រីប៉ូលីស និងរាជអាវុធហត្ថមួយចំនួន និងអ្នកភូមិប្រមាណ ៣០ នាក់ ។ ចៅក្រមស៊ើបអង្កេត នីល ណួន បានចំណាយពេលអស់ជាច្រើនថ្ងៃនៅខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការសំភាសន៏ ។ ប៉ុន្តែគេមានការបារម្ភថាអាចពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសមន្ត្រីប៉ូលីស និងកងរាជអាវុធហត្ថទាំងនោះដោយអ្នកភូមិពុំអាចស្គាល់ឈ្មោះកងកំលាំងទាំងនោះទេ[២៨] ។ មន្ត្រីប៉ូលីស និងកងរាជអាវុធហត្ថទាំងអស់ដែលត្រូវបានសួរចំលើយ បានអះអាងថា ពួកគេមិនបានបាញ់តម្រង់ទៅលើប្រជាពលរដ្ឋទេ ។

ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវបានគេសួរថា តើពួកគាត់បានដឹងអំពីរបាយការណ៏របស់គណៈ

កម្មការស៊ើបសួរដែរឬទេ ។ ពួកគាត់ទាំងពីរនាក់បានបញ្ជាក់ថា របាយការណ៍នោះពុំទាន់ត្រូវបានផ្តល់ទៅអោយពួកគាត់ជាផ្លូវការនៅឡើយទេ ។ ចៅក្រមស៊ើបអង្កេតបានធ្វើអត្ថាធិប្បាយបន្ថែមទៀតថា គាត់ចង់ធ្វើការស៊ើបអង្កេតដោយខ្លួនឯង[២៩] ។

នៅថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០០៥ តុលាការខេត្តបាត់ដំបងបានប្រកាសលើកលែងការចោទប្រកាន់ដល់ឈ្មោះតាន់ ភិរុន, ប៊ិន សំបិន ប៉ឬពៅ ផល្លី ដោយទាំង៣នាក់នេះត្រូវបានចាត់ទុកថាជានគរបាល។ បទចោទប្រកាន់បានបន្តចោទមន្ត្រីកងរាជអាវុធហត្ថម្នាក់ឈ្មោះនឹមផាន់ ប៉ុន្តែគេបានដោះលែងគាត់អោយនៅក្រៅឃុំបណ្តោះអាសន្ន ហើយបុរសបួននាក់ទៀតត្រូវបានដោះលែងទាំងអស់ ។ តាមរបាយការណ៍ក៏បានអោយដឹងផងដែរថា អ្នកភូមិដែលត្រូវបានជាប់ឃុំឃាំងនោះ ក៏ត្រូវបានលើកលែងការចោទប្រកាន់ផងដែរ ។

## *ការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាល*

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនរួមទាំងសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សផងបានចាប់ផ្តើមស៊ើបអង្កេតករណីនេះជាបន្ទាន់ ។ បច្ចុប្បន្នអង្គការអាដហុក កំពុងដឹកនាំការស៊ើបអង្កេតនៅក្នុងឧប្បទ្ទវហេតុនេះ និងកំពុងផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកភូមិមួយចំនួន រួមជាមួយនឹងជំនួយផ្នែកច្បាប់ដែលបានផ្តល់ដោយអង្គការគំរោងអ្នកការពារក្តីកម្ពុជា និង CCD ។ អង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀតបានជួយអ្នកភូមិតាមរយៈការធ្វើញត្តិជំនួសមុខអោយអ្នកភូមិ ថ្វាយព្រះមហាក្សត្រ ជូនក្រសួងយុត្តិធម៌ នាយករដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ[៣០] ។ អង្គការលីកាដូបានផ្តល់ការព្យាបាលជាបន្ទាន់បន្ទាប់ពីឧប្បទ្ទវហេតុបានកើតឡើងហើយបានសិក្សាករណីដីធ្លីនេះដែលនាំអោយមានការអនុវត្តន៍សាលក្រមដូច្នេះ ។

## *ស្ថានភាពបច្ចុប្បន្ន របស់សហគមន៍ក្បាលស្ពាន*

បន្ទាប់ពីមានការអនុវត្តន៍សាលក្រមអ្នកភូមិបានរុះរើទៅនៅកន្លែងមួយក្បែរដីរបស់កាស៊ីណូហ្គោលដិនក្រោនហើយបានសាងសង់ជំរកនៅជាបណ្តោះអាសន្ន។ ដោយការបាត់បង់សំភារៈផ្ទាល់ខ្លួនអស់ក្នុងពេលអនុវត្តន៍សាលក្រមពួកអ្នកភូមិពុំមានសំលៀកបំពាក់ គ្រឿងប្រដាប់ផ្ទះបាយសំរាប់ចំអិនអាហារ ទឹក ឬ អាហារសំរាប់បរិ-ភោគឡើយ ។ អាជ្ញាធរ ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់សំភារៈមួយចំនួនដល់អ្នកភូមិទាំងនោះ ។

នៅដើមខែ មេសា ឆ្នាំ ២០០៥ អ្នកភូមិបានវិលត្រលប់ទៅកាន់ក្បាលស្ពានវិញ បន្ទាប់ពីតំណាងកាស៊ីណូហ្គោលដិនក្រោន បានបញ្ជាអោយពួកគាត់ចាកចេញពីទីកន្លែងដែលពួកគាត់បានតាំងទីលំនៅជាថ្មី ដោយបានចោទប្រកាន់ថា អ្នកភូមិបានធ្វើអោយទឹកប្រឡាយក្រខ្វក់ ។ អ្នកភូមិបានវិលត្រលប់ទៅកាន់ដីចាស់របស់គាត់វិញដោយបានសាងសង់ផ្ទះរស់នៅជាបណ្តោះអាសន្ន ។

នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០០៥ អ្នកភូមិបានទាក់ទងអង្គការលីកាដូ ហើយប្រាប់ថា ពួកគាត់បានឮពាក្យចចាមអារ៉ាមថា នឹងមានការអនុវត្តន៍សាលក្រមម្តងទៀត ដែលនឹងត្រូវធ្វើនៅថ្ងៃទី ៨ ខែមិថុនា ។ នៅពេលសាកសួរព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យគាត់បានធានាអះអាង ថាពុំមានផែនការអនុវត្តន៍សាលក្រមបែបនេះឡើយ ។

មានសេចក្តីរាយការណ៍ដែរថាមានគ្រួសារថ្មីៗជាច្រើនបានចូលមកតាំងទីលំនៅក្នុងភូមិក្បាលស្ពាននេះដែលចំនួនពលរដ្ឋនៅពេលនេះបានកើនឡើងប្រមាណ៣០០គ្រួសារ ។ ដោយមានពាក្យចចាមអារ៉ាមអំពីកាសងផ្ទះសំបែងអោយអ្នកភូមិក្បាលស្ពាន ទើបបណ្តាលអោយប្រជាពលរដ្ឋថ្មីៗជាច្រើនគ្រួសារចូលមកតាំងទីលំនៅក្នុងភូមិនេះថែមទៀត[៣១] ។

តាមសេចក្តីរាយការណ៍របស់សារពត៌មានឌឹ ឃែមបូឌាដេលីថានៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៥ អាជ្ញាធរ ស្រុកអូរជ្រៅបានផ្តល់ដីមួយកន្លែងដល់អ្នកភូមិក្បាលស្ពានដែលស្ថិតនៅចំងាយ៤ គ.ម ពីក្បាលស្ពាន ប៉ុន្តែអ្នកភូមិបដិសេធមិនព្រមទទួលយក។ តំណាងភូមិម្នាក់ត្រូវបានដកស្រង់សំដី ដោយគាត់បាននិយាយថា ចំងាយឆ្ងាយពីព្រំដែនដែលធ្វើអោយថ្លៃដឹកជញ្ជូនកើនឡើង[៣២] ។ ប៉ុន្តែនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៥ កន្លងទៅនេះ លោកអភិបាលខេត្ត ហេង ចាន់ថា បានចុះហត្ថលេខាលើលិខិតមួយច្បាប់ដោយអនុញ្ញាតអោយប្រជាពលរដ្ឋបន្តតាំងទីលំនៅថ្មីតទៅទៀត ។

ជាចុងក្រោយ អ្នកភូមិមួយចំនួនបានសំដែងការព្រួយបារម្ភអំពីការហ្វឹកហ្វឺនស្តីពីការស្វែងរកមតិគាំទ្រដែលអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានហ្វឹកហ្វឺនដល់ពួកគាត់ ។ ពួកអ្នកភូមិមិនដឹងថាការហ្វឹកហ្វឺននោះមានប្រយោជន៍សំរាប់អ្វីទេ ហើយថែមទាំងមិនយល់អំពីហេតុផលនៃការហ្វឹកហ្វឺនេះថែមទៀតផង ។ ពួកគាត់បាននិយាយម្តងទៀតថា គោលបំណងសំខាន់របស់ពួកគេគឺធ្វើយ៉ាងណាអោយមានសិទ្ធិកាន់កាប់ដីដែលពួកគេកំពុងរស់នៅនេះស្របច្បាប់ ហើយចង់អោយមានប័ណ្ណកម្មសិទ្ធិដីធ្លីត្រឹមត្រូវដែលអាចធានាបាននូវកម្មសិទ្ធិភាពរបស់ពួកគាត់។ អ្នកភូមិទទួលស្គាល់ថាស្ថានភាពរបស់ពួកគាត់នៅតែមិនទាន់ច្បាស់លាស់នៅឡើយ ដូច្នេះហើយពួកគាត់នៅពុំទាន់មានសន្តិសុខអំពីអនាគតរបស់ខ្លួនទេ ហើយងាយទទួលរងការភ័យខ្លាចដោយពាក្យចចាមអារ៉ាមជាទីបំផុត ។

# អនុសាសន៍

ករណីក្បាលស្ពានគឺជាការព្រមានដ៏ធ្ងន់ធ្ងរមួយ ។ និន្នាការបច្ចុប្បន្នក្នុងការបំលាស់ទី និងការបណ្តេញចេញមានការពាក់ព័នយ៉ាងស្មុគស្មាញសំរាប់អនាគតប្រទេសកម្ពុជា ។ ប្រសិនបើបណ្តោយអោយមានបន្តទៀតដោយមិនកាត់បន្ថយទេ នោះនឹងមានការកើនឡើងនូវភាពអត់ផ្ទះសំបែង ភាពក្រីក្រ ភាពស្រេកឃ្លាន និងជំងឺដង្កាត់ផ្សេងៗជាច្រើនប្រភេទ។ ប្រសិនបើសហគមន៍មិនអាចស្វែងរកដំណោះស្រាយបានតាមរយៈតុលាការ ឬតាមរយៈរដ្ឋាភិបាលនោះទេពេលនោះនិន្នាការនេះទំនងជានឹងនាំអោយមានអំពើហិង្សាកាន់តែកើនឡើងថែមទៀតឥតឈប់ឈរ[៣៣] ។

## *រដ្ឋាភិបាល*

- រដ្ឋាភិបាលគួរធានាអោយមានសន្តិសុខដល់អ្នកភូមិទាំងឡាយដែលពាក់ព័ន្ធក្នុងករណីជំលោះដីធ្លីក្នុងភូមិក្បាលស្ពាននេះ ។
- រដ្ឋាភិបាលគួរធានាកុំអោយមានការប៉ុនប៉ងក្នុងការបង្ខំអោយប្រជាពលរដ្ឋចេញពីភូមិក្បាលស្ពាននេះ ។ ការផ្ទេរទីលំនៅ ទៅកន្លែងណាមួយគួរតែត្រូវធ្វើឡើងដោយមានការស្ម័គ្រចិត្តពីអ្នកភូមិនិងត្រូវអាស្រ័យទៅលើប្រជាពលរដ្ឋទាំងនោះក្នុងការទទួលយកដីថ្មីដែលត្រូវប្រគល់អោយ
- មន្ត្រីរដ្ឋាភិបាលណាដែលបានសន្យាជួយប្រជាពលរដ្ឋ គួររក្សាពាក្យសន្យារបស់ខ្លួន។
- ពីព្រោះបញ្ហាដីធ្លីនេះចេះតែកើតមានជាធម្មតានៅតំបន់ប៉ោយប៉ែតអំពើហិង្សាអាចនឹងកើតមាន
- ឡើងទៀត ដូច្នេះរដ្ឋាភិបាលគួរតែបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយដើម្បីស៊ើបអង្កេតនូវរាល់បញ្ហាជំលោះក្នុងពេលបច្ចុប្បន្ន និងករណី ដែលអាចកើតមានឡើងក្នុងពេលអនាគតនៅក្នុងតំបន់ប៉ោយប៉ែតនេះ ដោយសហការអោយបានល្អជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល។ ក្រសួងរៀបចំដែនដី និងនគររូបនីយកម្ម និងអង្គការមូលនិធិនានាដែលផ្តល់មូលនិធិដល់គំរោងជួយដល់ការគ្រប់គ្រងដីធ្លី គួរបង្កើតគំរោងប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីមួយនៅខេត្តបន្ទាយមានជ័យ រួមទាំងតំបន់កន្លែង ដែលជាតំបន់បន្ទាន់បំផុត ដូចជាប៉ោយប៉ែតផងដែរ ។
- មាត្រានៃច្បាប់ភូមិបាលឆ្នាំ ២០០១ និងអនុក្រិត្យអមនៃច្បាប់នេះចាំបាច់ត្រូវអនុវត្តអោយបានពេញលេញ ។ រាល់អនុក្រិត្យណាដែលត្រូវធ្វើសេចក្តីព្រាង គួរតែធ្វើឡើងអោយបានឆាប់ជាទីបំផុត ដោយមានការពិភាក្សាពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងប្រជាពលរដ្ឋដែលបានទទួលផលនៃអនុក្រិត្យនោះផង ។

- រដ្ឋាភិបាលគួរគោរពបទដ្ឋានអន្តរជាតិស្តីការបណ្តេញចេញដោយបង្ខំ និងសិទ្ធិមនុស្ស ដែលខ្លួនមានកាតព្វកិច្ចអនុវត្តផង ។

## វិជ្ជាជីវៈច្បាប់ និងតុលាការ

- ការស៊ើបអង្កេតរបស់តុលាការខេត្តបាត់ដំបងក្នុងករណីព្រហ្មទ័ណ្ឌដែលបានប្រព្រឹត្តិឡើងក្នុងការអនុវត្តន៍សាលក្រមនៅភូមិក្បាលស្ពានគួរតែបើកធ្វើសារជាថ្មីម្តងទៀត ។
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរពិនិត្យវិធានការរបស់តុលាការខេត្តបន្ទាយមានជ័យចំពោះករណីភូមិក្បាលស្ពាន រួមទាំងការសំរេចចេញសាលដីការពីរដែលចុះកាលបរិច្ឆេទដូចគ្នា ប៉ុន្តែមានការវាស់វែងទំហំដីទំនាស់ខុសគ្នាហើយដាក់ទណ្ឌកម្មដល់មន្ត្រីតុលាការណា ដែលបានប្រព្រឹត្តមិន
- ត្រឹមត្រូវ ។
- ការស៊ើបអង្កេតពេលអនាគត ចំពោះករណីស្រដៀងគ្នានេះ (ការបណ្តេញចេញ ដោយមាន
- អំពើហិង្សា) ជាពិសេសភាគីទាំងឡាយដែលត្រូវឡើងតុលាការ ចាំបាច់តំរូវអោយមានការយល់ដឹងអោយបានទូលំទូលាយ ។ មិនត្រឹមតែក្រុមគ្រួសាររបស់ជនរងរបួស ឬស្លាប់ប៉ុណ្ណោះទេ ក៏ប៉ុន្តែសាក្សីទាំងអស់ ដែលពាក់ព័ន្ធក្នុងការអនុវត្តន៍សាលក្រមនោះត្រូវធ្វើការសំភាសន៏ពួកគាត់អោយបានគ្រប់ៗគ្នាផង ។
- មេធាវីគួរធ្វើការដោយមានការពិគ្រោះយោបល់ល្អិតល្អន់ជាមួយកូនក្តីរបស់ខ្លួន ជូនដំណឹងដល់កូនក្តីជានិច្ច ។ ករណីដែលពាក់ព័ន្ធនឹងសហគមន៏គួរយល់ថាករណីបែបនេះ ជាករណីរបស់សហគមន៏ករណីរបស់កូនក្តីឬបុគ្គលណាមួយដែលទទួលបានសេវាផ្នែកច្បាប់នេះទេ ។ រាល់វិធានការ ដែលមេវីចាត់ការ គួរគិតគូរអោយបានហ្មត់ចត់ដល់ផលប្រយោជន៏សហគមន៏ ។
- ចំពោះអ្នកដែលត្រូវបង្ហាញខ្លួននៅតុលាការ គួរមានតំណាងផ្នែកច្បាប់ ។ ប្រសិនបើមេធាវីមកពីអង្គការផ្សេងៗគ្នា គួរចាត់អោយមានការប្រជុំជាប្រចាំ ដើម្បីពិភាក្សាករណី ។ ភស្តុតាង និងពត៌មាននានា គួរត្រូវបានចែកចាយអោយគ្នាទៅវិញទៅមកជាប្រចាំ ។
- កំណែទំរង់តុលាការ គឺជាការចាំបាច់ជាពិសេសចំពោះករណីទំនាស់ដីធ្លី ។ ត្រូវមានការស៊ើបអង្កេតអោយបានច្បាស់លាស់ច្រើនទៀត ។ ភាគីទាំងអស់ ជាពិសេសអ្នកដែលអាចបាត់បង់សិទ្ធិកាន់កាប់ដីធ្លីគួរមានតំណាង ដើម្បីជួយការពារដល់ខ្លួន ។

## អង្គការមិនមែនរដ្ឋាភិបាល

- មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានជួយសហគមន៍នានា ដែលទទួលការគំរាមកំហែង ។ ការងាររបស់អង្គការទាំងនោះត្រូវផ្តោតអោយចំៗគោលដៅ រួមសហការនឹងមានការសម្រប សម្រួលអោយបានច្រើន ។ញត្តិផ្សេងៗដែលធ្វើដោយអង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើអោយបាន ខ្ជាប់ខ្ជួន ។ រាល់វិធានការដែលចាត់ការឡើងត្រូវតែតាមដានរហូតដល់ទទួលបានលទ្ធផល និង រាល់វិធានការដែលបានចាត់ការមិនគួរធ្វើអោយខូចដល់ករណីតុលាការណាមួយដែលកំពុងរង់ចាំ ការវិនិច្ឆ័យសេចក្តីទេ ។
- អង្គការជំនាញដែលធ្វើការលើករណីជំលោះដីធ្លីនានា ត្រូវបង្កើតអោយមានបណ្តាញគោលនយោ បាយថ្នាក់ជាតិ ព្រមទាំងបណ្តាញនៅតាមខេត្តនានា ដើម្បីធ្វើការនៅថ្នាក់មូលដ្ឋាន។
- ករណីនានាដែលអង្គការមិនមែនរដ្ឋាភិបាលជាអ្នកចាត់ការគួរជំរាបអោយសហគមន៍បានដឹងជា ប្រចាំ និងលើកទឹកចិត្តអោយមានការចូលរួមយ៉ាងសកម្មនៅក្នុងដំណោះស្រាយដែលបានស្នើ ឡើង ។
- អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផ្តល់ការហ្វឹកហ្វឺនផ្នែកស្វែងរកការគាំទ្រមតិ និងកិច្ចអភិវឌ្ឍន៍ សហគមន៍ ដែលប្រហែលជាការចាំបាច់ ហើយត្រូវអនុវត្តដោយមានការយល់ដឹង នឹងចូលរួម អោយបានពេញលេញពីប្រជាពលរដ្ឋផង ។
- ស្ថានភាពសន្តិសុខ និងសុខភាពរបស់អ្នកភូមិនានាដែលត្រូវទទួលរងការគំរាមកំហែងត្រូវមាន ការពិនិត្យតាមដានជាប្រចាំ ។

## ទូទៅ

- ស្ថានភាពនៅក្នុងទីប្រជុំជនក្បែរតំបន់ព្រំដែនដូចជាប៉ោយប៉ែត ដែលតំលៃដីចេះតែកើនឡើងឥត ឈប់ឈរ ត្រូវមានការដោះស្រាយអោយបានឆាប់បំផុត ។ រាល់ផែនការអភិវឌ្ឍន៍ និងផែនការ ដូចគ្នានេះ គួរធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ដែលអាចរងផល ប៉ះពាល់ដោយផែនការនោះ ។ ផែនការទាំងឡាយគួរត្រូវបានរៀបចំឡើងតាមវិធីមួយដែល អាចមានផលចំណេញដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ផង ។
- ត្រូវមានយុទ្ធសាស្ត្រទូលំទូលាយមួយដើម្បីដោះស្រាយករណីដីធ្លីនានាដោយមានការចូលរួមពី សំណាក់រាជរដ្ឋាភិបាល សង្គមស៊ីវិល និង សហគមន៍ដែលមានផលប៉ះពាល់ផង ។
- ជាការចាំបាច់ត្រូវមានការហ្វឹកហ្វឺនច្បាប់ភូមិបាល ក្រៅផ្លូវការដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលមានកំរិតវប្បធម៌ទាប ឬគ្មានសោះ ។ ការហ្វឹកហ្វឺនមេធាវីអំពីច្បាប់ដីធ្លី នីតិវិធីក្នុងការធ្វើ

ប័ណ្ណកម្មសិទ្ធិដីធ្លី និងទទួលបានសំណងពេលដែលត្រូវទទួលរងការរំលោភកម្មសិទ្ធិកាន់កាប់ដីធ្លី នោះក៏មានការចាំបាច់ផងដែរ ។

- សហគមន៍ដែលស្ថិតក្រោមការគំរាមកំហែងពីការបណ្តេញចេញ ឬអនុវត្តសាលក្រម ត្រូវមានការពិគ្រោះអំពីចំណង់ និង តំរូវការនានារបស់ពួកគាត់ ។ រាល់ការចាត់វិធានការដោយអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលគួរត្រូវបានអនុវត្តដោយមានការចូលរួមយ៉ាងពេញលេញរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ។
- មានរបាយការណ៍ សិក្ខាសាលា និងសន្និសិទមួយចំនួនស្តីពីបញ្ហាដីធ្លីនៅកម្ពុជា ។ របាយការណ៍រួមមានអនុសាសន៍នានាស្តីពីរបៀបដោះស្រាយបញ្ហាជំលោះដីធ្លីនៅកម្ពុជា។ អនុសាសន៍ទាំងនេះគួរត្រូវបានពិនិត្យនឹងអនុវត្ត[៣៤] ។

# កាលប្បវត្តិ

| | |
|---|---|
| ១៩៩៧ | អ្នកភូមិក្បាលស្ពានដោះមីនតំបន់ក្នុងភូមិ ហើយអាជ្ញាធរបានចេញសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ និង ចំនួនផ្ទះពិតប្រាកដ ។ |
| ១៨ មិថុនា ១៩៩៨ | ទិន អូន ដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លី ( ដើម្បីប្រើប្រាស់និងកាន់កាប់ដីក្បាលស្ពា ) ពីអគ្គនាយកដ្ឋានសុរិយោដី ។ |
| ដើមឆ្នាំ ១៩៩៩ | ទិន អូន ប្តឹងសុំកាន់កាប់កម្មសិទ្ធិទៅតុលាការខេត្តបន្ទាយមានជ័យ ។ |
| ១៨ វិច្ឆិកា ១៩៩៩ | ទិន អូន បានទទួលប័ណ្ណកម្មសិទ្ធិដីក្បាលស្ពានពីតុលាការខេត្ត |
| ១៥ មករា ២០០០ | តំណាងក្រសួងទំនាក់ទំនង សភា-ព្រឹទ្ធសភា និងអធិការកិច្ចបានជួបជាមួយប្រជាពលរដ្ឋនៅក្បាលស្ពាន និងពិនិត្យមើលដីមេឃុំប៉ោយប៉ែត រស់ សារ៉ុន  ព្រមទាំងបានចេញលិខិតមួយច្បាប់បញ្ជាក់ថាមានប្រជាពលរដ្ឋចំនួន ២១៨ គ្រួសារកំពុងរស់នៅក្នុងក្រុមទី ៥៥ ភូមិក្បាលស្ពាន ៥ ឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ។ |
| ១៧ កម្ភៈ២០០១ | សាលាឧទ្ធរណ៍ចេញសាលដីកាសំរេចបញ្ជាក់ពីប័ណ្ណកម្មសិទ្ធិរបស់ ទិន អូន |
| ២៤-២៦ មេសា ២០០២ | តុលាការខេត្តបន្ទាយមានជ័យអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ ហើយបង្ខំអោយប្រជាពលរដ្ឋថយចេញពីដីនោះ ។ ប្រជាពលរដ្ឋបានផ្លាស់ទៅតាំងទីលំនៅក្នុងភូមិមួយក្បែរភូមិចាស់នោះ ។ |
| ២៤ ឧសភា ២០០២ | ការិយាល័យសុរិយោដីស្រុកអូជ្រៅ ចេញលិខិតមួយច្បាប់បញ្ជាក់ថា ពាក្យសុំប័ណ្ណកម្មសិទ្ធិរបស់ ទិន អូន ចុះថ្ងៃទី ១៨ មិថុនា ១៩៩៨ មិនទាន់ត្រឹមត្រូវ ហើយដូច្នេះពុំអាចចុះបញ្ជីនៅការិយាល័យសុរិយោដីបានទេ ។ |
| ចុង ២០០២ ដើម ២០០៣ | អ្នកភូមិនិយាយថា ទិន អូន បានប្រាប់ពួកគាត់ថា  គាត់នឹងអោយដីនោះមកវិញជាថ្នូរនឹងសន្លឹកឆ្នោត ដែលបោះអោយគណបក្សនយោបាយរបស់គាត់ ។ ប្រជាពលរដ្ឋយល់ព្រម ហើយវិលត្រឡប់មករស់នៅលើដីនោះវិញដោយពុំមានបញ្ហាកើតឡើង ។ |
| កញ្ញា ២០០៣ | ទិន អូន ប្តឹងតំណាងភូមិ ៦ នាក់ពីបទដើរកាត់ដី ។ តំណាងពីរនាក់ត្រូវបានគេចាប់ចង និង ឃុំខ្លួន ។ |
| វិច្ឆិកា ២០០៣ | អង្គការជំនួយផ្នែកច្បាប់កម្ពុជា បានជួយតំណាងទាំងពីរនាក់ ព្រមទាំងជួយអោយមានការដោះលែងដោយប្តឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានបញ្ជាអោយដោះលែង ។ |
| ធ្នូ ២០០៣ | តុលាការខេត្តប៉ុនប៉ងអនុវត្តសាលក្រមម្តងទៀត ប៉ុន្តែមិនបានសំរេច ។ |

| | |
|---|---|
| កុម្ភៈ ២០០៥ | ទិន អូន ស្នើទៅតុលាការខេត្តបន្ទាយមានជ័យអោយអនុវត្តសាលក្រមរបស់ខ្លួនជាលើក ទី ៣ ។ |
| មិនា ២១ | ការអនុវត្តន៍សាលក្រមបណ្តេញចេញបានកើតឡើង ហើយអំពើហិង្សាក៏ផ្ទុះឡើងដែរ ដែលបណ្តាលអោយអ្នកភូមិ ៥ នាក់ស្លាប់ ។ |
| ចុងខែ មិនា | គណៈកម្មការស៊ើបសួររបស់រដ្ឋាភិបាលស៊ើបអង្កេតព្រឹត្តិការណ៍បណ្តេញចេញនោះ ។ |
| ដើម ខែ មេសា ២០០៥ | តុលាការស៊ើបអង្កេតអំពើហិង្សាត្រូវបានក្រសួងយុត្តិធម៌ផ្ទេរសិទ្ធិពីតុលាការ ខេត្តបន្ទាយមានជ័យ អោយទៅតុលាការ ខេត្តបាត់ដំបង ។ ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបងចោទប្រកាន់មនុស្សជាង ១០០ នាក់ពីបទមនុស្សឃាត ទៅបទវាយដំលើរាងកាយ ។ មន្រ្តីនគរបាល ២ នាក់ កងរាជអាវុធហត្ថ ១ នាក់ និងបុរស ១ នាក់ (ពាក់ព័ន្ធក្នុងជំលោះ) ត្រូវបានចាប់ និង ឃុំខ្លួន ។<br>អ្នកភូមិក្បាលស្ពានត្រឡប់មករស់នៅភូមិដែលគេបណ្តេញពួកគាត់ចេញវិញ ក្រោយពីត្រូវបានបញ្ជាអោយថយចេញពីដីដែលពួកគាត់រស់នៅក្រោយការអនុវត្តសាលក្រម ។ |
| កក្កដា ២០០៥ | អាជ្ញាធរស្រុកបានសុំអោយប្រជាពលរដ្ឋទៅនៅភូមិថ្មីមួយដែលមានចំងាយ ៤ គីឡូ-ម៉ែត្រ ។ ប្រជាពលរដ្ឋបដិសេធសំណើរបស់អាជ្ញាធរដោយនិយាយថាដីនោះឆ្ងាយពេក ។ |
| ៤ សីហា ២០០៥ | តុលាការខេត្តបាត់ដំបងលើកលែងការចោទប្រកាន់ដល់បុរស ៣ នាក់ ដោយពិពណ៌នាថាទាំង ៣ នាក់នោះជាកងកំលាំងនគរបាល ហើយបានត្រូវឃុំឃាំងបណ្តោះអាសន្ន ។ មានសេចក្តីរាយការណ៍ថាតុលាការនៅតែបន្តចោទប្រកាន់កងរាជអាវុធហត្ថម្នាក់ ប៉ុន្តែគាត់ ត្រូវតុលាការដោះលែងអោយនៅក្រៅឃុំ ។ តែមានសេចក្តីរាយការណ៍មកថាតុលាការបានលើកលែងការចោទប្រកាន់ដល់កងកំលាំងសន្តិសុខ និង អ្នកភូមិទាំងអស់គ្នាផងដែរ ។ |
| ១១ សីហា ២០០៥ | អភិបាលខេត្ត លោក ហេង ចាន់ថា ចុះហត្ថលេខាលើលិខិតមួយច្បាប់អនុញ្ញាតអោយសំណើសុំតាំងទីលំនៅចុងក្រោយបន្តធ្វើតទៅទៀត ។ |

# កំណត់សំគាល់

១- នីតិវិធីបច្ចុប្បន្នត្រូវបានកំណត់ដោយអនុក្រិត្យស្តីពីការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីដែលមិនពាក់ព័ន្ធ ហើយរួមមាន ១៦ ជំហានដែលមានអាជ្ញាធរច្រើនប្រភេទពាក់ព័ន្ធ ។

២- Cooper, "គោលការណ៍ដីធ្លី និង ទំនាស់" ទំព័រ ៥. William, "ទំនាស់កម្មសិទ្ធិដីធ្លីនៅកម្ពុជា" ទំព័រ ៧-៩។

៣- ពត៌មានភាគច្រើននៅក្នុងភាគនេះត្រូវបានដកស្រង់ចេញពីកំណត់សំគាល់ និង អ៊ីម៉ែលពីភ្នាក់ងារ និងអង្គការនានារួមទាំងឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សរសេរដោយ Dr. Claude Katz, ADHOC, LICADHO, ZOA និង អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតបឋមនៃស្ថានភាពភូមិក្បាលស្ពាន ។ ចំណុចសំខាន់ត្រូវកត់សំគាល់ថា អង្គការ ឬភ្នាក់ងារភាគច្រើនចាប់ផ្តើមធ្វើការលើករណីក្បាលស្ពានក្រោយពេលដែលមានសេចក្តីសំរេចរបស់តុលាការ ខេត្តបន្ទាយមានជ័យ និងសាលាឧទ្ធរណ៍តែប៉ុណ្ណោះ ។

៤- ចំនួនគ្រួសារបានកើនឡើងរវាងឆ្នាំ ១៩៩៩ និង ២០០០ ហើយប្រជាពលរដ្ឋដែលរស់បច្ចុប្បន្នមួយចំនួនបាននិយាយថាពួកគាត់បានទិញដីពីពលរដ្ឋផ្សេងៗទៀតដែលបានដោះមីនរួចរាល់អស់ហើយ ។

៥- របាយការណ៍ដោយការិយាល័យខេត្តបាត់ដំបង នៃឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាក្នុងខែកក្កដា ឆ្នាំ២០០១។

៦- ពត៌មានផ្តល់ដោយមនុស្សមួយចំនួន ដែលមិនហ៊ានប្រាប់ឈ្មោះមន្ត្រីជាន់ខ្ពស់ដែលត្រូវបានចោទប្រកាន់ថាបានចូលរួមពាក់ព័ន្ធក្នុងនោះដែរ ហើយក៏មិនចង់អោយមានការដកស្រង់សំដីជាប្រភពពត៌មានដែរ។

៧- បញ្ជាក់នៅក្នុងរបាយការណ៍របស់ព្រឹទ្ធសភាម្នាក់ឈ្មោះ សេង អឿន ដែលមានចំណងជើងថា "សាលក្រមក្លែងក្លាយលេខ ១៦៨ របស់តុលាការខេត្តបន្ទាយមានជ័យ" ។

៨ -មាត្រា ១៩ នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២ បានចែងថា ទ្រព្យសម្បត្តិតែមួយគត់ដែលអាចជាកម្មសិទ្ធិ គឺផ្ទះសំបែង។ សេចក្តីណែនាំលេខ ០៣ របស់ក្រុមប្រឹក្សារដ្ឋនៃក្រុមប្រឹក្សារដ្ឋមន្ត្រី (១៩៨៩) ចែងថា ដីលំនៅដ្ឋានអាចមានទំហំ ២.០០០ ម៉ែត្រទ្វេគុណ ប៉ុន្តែដី ដែលផ្តល់អោយសំរាប់ការដាំដុះមិនត្រូវអោយលើសពី ៥ហិកតាទេ។ តុលាការបានរំលោភលើសេចក្តីណែនាំលេខ ០៣ ដោយបានផ្តល់អោយ ឈ្មោះទិន អូន នូវដីទំហំប្រមាណ ៦ ហិកតាដើម្បីប្រើប្រាស់ក្នុងការដាំដុះ ។ ដកស្រង់ពីរបាយការណ៍របស់ព្រឹទ្ធសភា សេង អឿនដែលមានចំណង ជើងថា "សាលក្រមក្លែងក្លាយរបស់តុលាការខេត្តបន្ទាយមានជ័យ" ។

៩- របាយការណ៍របស់ សេង អឿន ដែលមានចំណងជើងថា "សាលក្រមក្លែងក្លាយលេខ ១៦៨ របស់តុលាការខេត្តបន្ទាយមានជ័យ" ។ មានមាត្រាតែមួយគត់នៅក្នុងច្បាប់ស្តីពីមុខងាររបស់តុលាការអំពីការកែតំរូវសាលក្រម ដែលតាមបច្ចេកទេសអាចអនុវត្តបានលើករណីព្រហ្មទ័ណ្ឌតែប៉ុណ្ណោះ ។ មាត្រានេះត្រូវបានប្រើប្រាស់នៅ

ក្នុងករណីរដ្ឋប្បវេណីនានាដោយតុលាការ ហើយតំរូវអោយភាគីដែលមានផលប្រយោជន៏ក្នុងករណីអោយធ្វើបណ្តឹងទៅតុលាការនៅជំហានដំបូងដើម្បីបដិសេធនូវសាលក្រមក្លែងក្លាយនោះ ហើយស្នើសុំអោយចេញសាលក្រមថ្មីមួយទៀត ។ ឯកសារដែលបានផ្តល់អោយ ព្រឹទ្ធសភា សេង អឿនបានលើកឡើងថាការកែតំរូវទំហំដីនៅក្នុងសាលក្រមគួរត្រូវបានកត់ត្រាទុកអោយបានត្រឹមត្រូវ ហើយគួរតែបានបញ្ជាក់អោយបានច្បាស់អំពីច្បាប់ដែលអនុញ្ញាតអោយចៅក្រមកែតំរូវសាលក្រមនោះផង ព្រមទាំងហេតុផលក្នុងការកែតំរូវនោះ ។ គួរកត់សំគាល់ផងដែរថា តាមគណៈកម្មការទំនាស់ដីធ្លីខេត្ត ការិយាល័យសុរិយោដី និងប្រជាពលរដ្ឋមួយចំនួនដែលមានព្រំជាប់នឹងដី ។ គួរធ្វើប្លង់គោលថ្មីមួយ ដែលមានរៀបរាប់ ពីទំហំដីត្រឹមត្រូវ និងព្រំប្រទល់របស់ដីនោះ ។ ប្លង់គោលនេះគួរបានកត់ត្រារក្សាទុកត្រឹមត្រូវដោយ ភាគីទាំងពីរ ព្រមទាំងប្រជាពលរដ្ឋ ដែលរស់នៅលើដីដែលមានព្រំប្រទល់ជាប់នឹងដីនោះផង ហើយត្រូវផ្តិត មេដៃទុកជាចំណាំនៅលើប្លង់ ដើម្បីទទួលស្គាល់ភាពត្រឹមត្រូវ ។ សាលក្រមដែលបានកែតំរូវគួរកែតំរូវតំលៃដីដើម្បីអោយសមនឹងទំហំដី កែថ្មីនោះផងដែរ ។

១០- បញ្ជាក់នៅក្នុងរបាយការណ៏របស់ព្រឹទ្ធសភា សេង អឿន ដែលមានចំណងជើងថា "សាលក្រមក្លែងក្លាយលេខ ១៦៨ របស់តុលាការខេត្តបន្ទាយមានជ័យ" ។

១១- លិខិតបញ្ជាក់(វិញ្ញាបនប័ត្រ)ទទួលបានដោយអង្គការជំនួយផ្នែកច្បាប់នកម្ពុជាដើម្បីប្រើនៅក្នុងករណីព្រហ្ម ទ័ណ្ឌដែលប្តឹងអ្នកភូមិ ២ នាក់ចំពោះការរំលោភលើទ្រព្យសម្បត្តិឯកជន (ឆ្នាំគឺត្រឹមត្រូវ ប៉ុន្តែកាលបរិច្ឆេទចាំមិនច្បាស់លាស់ទេ)។

១២- ពត៌មានទទួលបានពីការវិភាគរបស់បុគ្គលិកលីកាដូ ។

១៣- អភិបាលរងស្រុកបានបញ្ជាអោយ ទិន អួន មកបំពេញទំរង់ត្រឹមត្រូវនៅឯការិយាល័យសុរិយោដីស្រុក ដូច្នេះគាត់អាចទទួលបានការទទួលស្គាល់ជាផ្លូវការដែលគាត់បានប្រើប្រាស់ដីចាប់តាំងពី ថ្ងៃទី ១០ ខែមេសា ១៩៩៩ ប៉ុន្តែ ទិន អួន ពុំបានមកបំពេញទេ ។

១៤- សំភាសន៏ជាមួយក្រឡាបញ្ជី ចាន់ សាវ៉ាត នៅតុលាការបន្ទាយមានជ័យនៅថ្ងៃទី ១៩ ឧសភា ឆ្នាំ ២០០៥ ។

១៥- ក្រុមទី ១ រួមមាននគរបាលព្រំដែនចំនួន ១៥ នាក់ ដឹកនាំដោយលោក ហ៊ឹម ឆុង អនុប្រធាន (អង្គភាពលេខ ៨៩១) ។ ក្រុមទី ២ រួមមានកំលាំងកងរាជអាវុធហត្ថព្រំដែនចំនួន ៤២ នាក់ដឹកនាំដោយលោកវរសេនីត្រីយ៏ ស្រួយ ប៉ែន និងនគរបាលស្រុកអូជ្រៅចំនួន ១២ នាក់ដឹកនាំដោយអធិការរងនគរបាលស្រុក ឈ្មោះសុំ សូភិន ។ ក្រុមទី៣ រួមមានកំលាំងនគរបាលខេត្តចំនួន ៤០ នាក់ដឹកនាំដោយលោក វរសេនីត្រីយ៏ វិន សៀន និងលោក វរសេនីយ៏ទោ សៀង ណុល ។ ក្រុមចុងក្រោយមានកំលាំងនគរបាលព្រំដែនចំនួន ១៥ នាក់ ដឹកនាំដោយមេបញ្ជាការ ឈួង អាង ។

១៦- សាក្សីមានការព្រួយបារម្ភអំពីសន្តិសុខ និង សុំមិនបញ្ចេញឈ្មោះ ។ គាត់បានបញ្ជាក់ផងដែរថា គាត់នឹងឡើងឆ្លើយនៅមុខតុលាការលុះត្រាតែខ្លួនគាត់ នឹងគ្រួសាររបស់គាត់ត្រូវបានធានានូវសុវត្ថិភាពត្រឹមត្រូវ ។ សំដីរបស់គាត់ដែលនិយាយថាក្រឡាបញ្ជីអានសាលក្រមក្រោយពេលដែលមានការបាញ់កើតឡើងនោះ សំដី

នេះក៏ត្រូវបានការស៊ើបអង្កេតរបស់លីកាដូ និង គណៈកម្មាធិការប្រព្រឹត្តិកម្ម ព្រមទាំងសាក្សីមួយចំនួនទៀតគាំទ្រផងដែរ ។

១៧- សំភាសន៍ជាមួយ ងួន ថុល និង ចាន់ សាវ៉ាត នៅតុលាការខេត្តបន្ទាយមានជ័យថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

១៨- កាសែត ឌឺ ឃែមបូឌាដេលី ចុះថ្ងៃទី ២២-២៣ ខែមិនា ឆ្នាំ ២០០៥ និង កាសែតភ្នំពេញប៉ុស្តិ៍ ២៥ ខែមិនា - ៧ ខែមេសា ២០០៥ ។

១៩- អាយុ ២៣ ឆ្នាំ រស់នៅ ភូមិខាំផ្អែ ឃុំតាឡាំ ស្រុកមង្គលបូរី ។

២០- ដូចដែលបានកត់ត្រា ។

២១- គណបក្សសមរង្ស៊ីក៏បានផ្តល់ថ្នាំពេទ្យ អង្ករ ថវិកា និង សំភារៈមួយចំនួនទៀតដល់អ្នកភូមិ ។ គណបក្សសមរង្ស៊ីក៏បានសរសេររបាយការណ៍មួយច្បាប់ស្តីពីការអនុវត្តន៍សាលក្រមនោះដែរ ដែលរួមមានរូបថតកងកំលាំង ដែលមិនស្គាល់ស្លៀកពាក់ក្នុងឯកសណ្ឋានពណ៌ប្រផេះចាស់ ។

២២- កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី ២៣ ខែមិនា ឆ្នាំ ២០០៥ ។

២៣- ដកស្រង់ពីកាសែត ឌឺ ឃែមបូឌាដេលី ថ្ងៃទី ២៤ ខែមិនា ឆ្នាំ ២០០៥ ។

២៤- គណៈកម្មការរួមមានលោក សុខ សារ៉េត ( អភិបាលរង ) ជាប្រធាន, លោក អាត ខេម ( ស្នងការនគរបាល) និងលោក រដ្ឋ ស្រ៊ាង ( បញ្ជាការកងរាជអាវុធហត្ថ) ជាអនុប្រធាន ។ សមាជិករួមមានៈ លោក ឆឹង សុខុម ( បញ្ជាការរងនគរបាល), លោក កែវ សេន ( អភិបាលស្រុកអូជ្រៅ ), ញឹក ចំរើន ( បញ្ជាការយោធាខេត្ត) និងលោក ហៃ ណាំហេង ( មេឃុំប៉ោយប៉ែត) ។

២៥-តុលាការខេត្តបន្ទាយមានជ័យសុំស្នើកំលាំងកងរាជអាវុធហត្ថ និង នគរបាលចំនួន ២៣០ នាក់ ប៉ុន្តែទទួលបានត្រឹមតែ ១២៤ នាក់ប៉ុណ្ណោះ កំលាំងទាំងអស់ប្រដាប់ដោយអាវុធគ្រប់ដៃ ។ មានកំលាំងនគរបាលខេត្តចំនួន ៤០ នាក់ កំលាំងនគរបាលស្រុកចំនួន ១២ នាក់ និងនគរបាលព្រំដែនចំនួន ៣០ នាក់ ។

២៦- អាយុ ២៣ ឆ្នាំ រស់នៅភូមិ ខាំផ្អែ ឃុំតាឡាំ ស្រុកមង្គលបូរី ។

២៧-ទាំងព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតពុំអាចដឹងច្បាស់ថាកំលាំងកងរាជអាវុធហត្ថ និងនគរបាលប៉ុន្មាននាក់ព្រមទាំងមិនដឹងថាប្រជាពលរដ្ឋប៉ុន្មានទេ ដែលត្រូវបានចោទប្រកាន់ ។ បញ្ជីឈ្មោះអ្នកដែលត្រូវបានចោទប្រកាន់នោះមិនបានបង្ហាញនូវលក្ខណៈសំគាល់ណាមួយទេ ។ តួលេខនេះទទួលបានដោយការប្រៀបធៀបបញ្ជីអ្នកភូមិ និងបញ្ជីអ្នកដែលត្រូវបានចោទប្រកាន់ ។

២៨- ជួបជាមួយ យ៉ម យ៉េត នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៥ ។

២៩- ជួបជាមួយ និល ណុន ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៥ និងយ៉ម យ៉េត ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៥។

៣០- ក្រសួងយុត្តិធម៌បដិសេធញត្តិអាស្រ័យដោយករណីត្រូវបានព្យួរនៅតុលាការ ។ អង្គការមិនមែនរដ្ឋាភិបាល២ បានផ្ញើញត្តិទៅនាយករដ្ឋមន្ត្រី ។ អង្គការមួយបានរាយការណ៍ថានាយករដ្ឋមន្ត្រីបានយល់ព្រមជួបជាមួយពួកគេ ដើម្បីពិភាក្សាអំពីករណីនេះ ប៉ុន្តែពុំបានកំណត់កាលបរិច្ឆេទទេ ។

៣១ - ពតិមានផ្តល់ដោយ CHO ។

៣២-ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ ។ "គ្រួសារដែលត្រូវបណ្តេញចេញបដិសេធមិនព្រមទៅតាំងទីលំនៅលើដីថ្មី "ទំព័រ ១៥ ។

៣៣- ដូចដែលលោក ធន សារ៉ាយ ប្រធានអាដហុកបាននិយាយ "ប្រសិនបើរដ្ឋាភិបាល មិនខ្វាយខ្វល់អំពីបញ្ហានេះ ខ្ញុំគិតថាភាពតានតឹង អំពើហិង្សានឹងត្រូវកើនយ៉ាងច្រើនថែមទៀត "។ ហើយស្ថានភាពនយោបាយ នឹងត្រូវគ្មានស្ថេរភាពផងដែរ ប្រសិនបើខ្វះខាតស្ថានភាពសង្គម និង សេដ្ឋកិច្ចបែបនេះ" ។ ដកស្រង់ចេញពី "ការអនុវត្តសាលក្រមជាការដុតបញ្ឆេះសង្គមអោយមានភាពច្របូកច្របល់នៅកម្ពុជា " សរសេរដោយ Katz Woodsome, ថ្ងៃទី ៧ ខែមេសា ឆ្នាំ២០០៥ ។

៣៤- សូមមើល"ឧទាហរណ៍William Shaun "តើដីបាត់ទៅណា ? សិទ្ធិកាន់កាប់ដីធ្លី និង ការទទួលបាននៅកម្ពុជា " ។ Oxfarm GB ខែ ឧសភា ឆ្នាំ ១៩៩៩ របាយការណ៍សន្និសិទស្តីពីសិក្ខាសាលាជាតិស្តីពីការបង្កើតកិច្ចសហប្រតិបត្តិការអំពីការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា -ខែ កក្កដា ឆ្នាំ ១៩៩៩ រៀបចំដោយ Oxfarm GB និង អាដហុក-សរសេរដោយ William Shaun ទំនាស់កម្មសិទ្ធិដីធ្លីនៅកម្ពុជា" ការសិក្សាអំពីសមត្ថភាពខេត្តចំនួន ៥ ក្នុងការដោះស្រាយទំនាស់ដីធ្លី " Oxfarm GB ។ ខែ កុម្ភៈ ឆ្នាំ ២០០០ សរសេរដោយ Palmer David/Torhnen Kika-Petteri ។ ការគ្រប់គ្រងដីធ្លីក្រោយជំលោះនៅកម្ពុជា "សន្និសិទរៀបចំដោយអង្គការ FAO ស្តីពីការគ្រប់គ្រងដីធ្លីតំបន់ក្រោយជំលោះនៅទីក្រុង Geneva ខែ មេសា ឆ្នាំ ២០០៤ សរសេរដោយ Cooper Geoge W., "គោលការណ៍ដីធ្លី និង ជំលោះ" ខែមិនា ឆ្នាំ២០០២ (សរសេរឡើងវិញនៅខែមិថុនា ឆ្នាំ២០០៤) និង Leuprecht, Peter សម្បទានដី សំរាប់គោលបំណងសេដ្ឋកិច្ច "ទស្សនៈសិទ្ធិមនុស្ស" តំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស " ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។